ខុមហ្វ្រែល COMFREL

# របាយការណ៍ស្តីពីការសង្កេតការចុះឈ្មោះបោះឆ្នោត និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩







កុម្ភៈ ២០២០

របាយការណ៍

ស្ដីពី

# ការសង្កេតការចុះឈ្មោះបោះឆ្នោត
# និងសវនកម្មបញ្ជីឈ្មោះបោះឆ្នោត
# ឆ្នាំ២០១៩

# មាតិកា


សទ្ទានុក្រម ........ 2

សេចក្ដីសង្ខេប ........ 3

សង្ខេបការរកឃើញ ........ 4

ការសង្កេត និងការធ្វើសវនកម្ម ........ 6

ក. ការរៀបចំដំណើរការចុះឈ្មោះបោះឆ្នោត ........ 6

ខ. ការបង្កើតការិយាល័យបោះឆ្នោត និងស្ថិតិប្រជាពលរដ្ឋក្នុងការចុះឈ្មោះបោះឆ្នោត ........ 7

គ. បរិយាកាសទូទៅទាក់ទងការចុះឈ្មោះបោះឆ្នោត ........ 12

ឃ. ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ........ 15

ង. ការសម្ភាសន៍ប្រជាពលរដ្ឋ ........ 30

ច. ការឆ្លើយតបតំណាងក្រុមការងារបច្ចេកទេសតំណាងឱ្យស្ថាប័ន គ.ជ.ប ........ 37

ឆ. បញ្ហាប្រឈម និងដំណោះស្រាយ ........ 38

# សទ្ទានុក្រម

| | |
|---|---|
| **គ.ជ.ប** | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត |
| **ខុមហ្វ្រែល** | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌ នៅកម្ពុជា |
| **អ.ខ** | អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ |
| **ឯ.អ** | ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត |
| **ទិន្នន័យ** | សំដៅលើព័ត៌មានទាំងអស់របស់អ្នកបោះឆ្នោតម្នាក់ដែលបានផ្ទុកក្នុងប្រព័ន្ធមួយសម្រាប់ប្រើប្រាស់ ដូចជាឈ្មោះ ថ្ងៃខែឆ្នាំកំណើត រូបថត ស្នាមក្រយ៉ៅដៃ អាសយដ្ឋាន។ល។ |
| **អ្នកចុះឈ្មោះថ្មី** | ប្រជាពលរដ្ឋដែលទើបគ្រប់អាយុចុះឈ្មោះបោះឆ្នោត ក្នុងពេលវេលាកំណត់ ឧទាហរណ៍ ប្រជាពលរដ្ឋខ្មែរទើបគ្រប់អាយុ១៨ឆ្នាំ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ អាចមកចុះឈ្មោះក្នុងឆ្នាំ២០១៩បាន។ |
| **ឈ្មោះស្ទួន** | ជាឈ្មោះដែលមានព័ត៌មានសំខាន់ៗរបស់អ្នកបោះឆ្នោតក្នុងទិន្នន័យដូចគ្នាច្រើន ដូចជាឈ្មោះដូចគ្នា ថ្ងៃខែឆ្នាំកំណើតដូចគ្នា លេខអត្តសញ្ញាណប័ណ្ណដូចគ្នា រូបថតដូចគ្នា |
| **ឈ្មោះខ្មោច** (Ghost Voter) | ជាអ្នកមានសិទ្ធិបោះឆ្នោតមិនមានវត្តមានដូចទីតាំងដែលបានកំណត់ក្នុងបញ្ជីបោះឆ្នោតគឺមានតែឈ្មោះក្នុងបញ្ជី តែគ្មានអ្នកស្គាល់។ |
| **សវនកម្មបញ្ជីឈ្មោះ** | ធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់លើបញ្ជីឈ្មោះដើម្បីឱ្យដឹងពីព័ត៌មានអ្វីមួយ |
| **អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោត** | សំដៅលើប្រជាពលរដ្ឋដែលមានអាយុពី១៨ឆ្នាំឡើងគិតត្រឹមថ្ងៃបោះឆ្នោត ឬអាយុ១៨ឆ្នាំត្រឹមថ្ងៃកំណត់ដោយ គ.ជ.ប សម្រាប់ចុះឈ្មោះ |
| **អ្នកមានសិទ្ធិបោះឆ្នោត** | ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត |
| **អ្នកបានបោះឆ្នោត** | ជាប្រជាពលរដ្ឋបានបោះឆ្នោតរួចក្នុងថ្ងៃបោះឆ្នោត |
| **ស្ថិតិប៉ាន់ប្រមាណ** | ជាចំនួនមួយដែលធ្វើការសន្និដ្ឋានទុកជាមុន តែតម្លៃនេះអាចមិនពិត១០០ភាគរយដូចអ្វីដែលបានលើកឡើងនោះទេ |
| **ការិយាល័យ** | ជាទីកន្លែងកំណត់សម្រាប់ចុះឈ្មោះ ឬបោះឆ្នោត |

# សេចក្តីសង្ខេប


របាយការណ៍សង្កេតការពិនិត្យបញ្ជីឈ្មោះ ការចុះឈ្មោះបោះឆ្នោត និងការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ជាលទ្ធផលនៃការសង្កេតការចុះឈ្មោះបោះឆ្នោតឆ្នាំទី៤ គិតពីឆ្នាំ២០១៦មក។ ក្នុងដំណាក់កាលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ខុមហ្វ្រែលមិនបានដាក់ពង្រាយអ្នកសង្កេតការណ៍ចំនួនច្រើនក្នុងការឃ្លាំមើលដំណាក់កាលចុះឈ្មោះនោះទេ រួមទាំងការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតពីបញ្ជីទៅមនុស្សផង។

ការចុះឈ្មោះបោះឆ្នោតត្រូវបានចុះឡើងវិញជាមួយប្រព័ន្ធកុំព្យូទ័រ ចាប់ពីឆ្នាំ២០១៦។ តួលេខនៃការចុះឈ្មោះបោះឆ្នោតចាប់ពីឆ្នាំ២០១៧ មកដល់ឆ្នាំ២០១៩ មានការធ្លាក់ចុះជាបន្តបន្ទាប់បើប្រៀបធៀបជាមួយស្ថិតិប៉ាន់ប្រមាណប្រចាំឆ្នាំ។ យោងលើស្ថិតិរបស់ក្រសួងការងារ រួមទាំងស្ថិតិអង្គការសង្គមស៊ីវិលក្រៅផ្លូវការ មានប្រជាពលរដ្ឋចំណាក់ស្រុកទៅធ្វើការនៅក្រៅប្រទេសប្រមាណជាង ២លាននាក់ ដែលពួកគេភាគច្រើន ខុមហ្វ្រែល បានសង្កេតឃើញថាមិនទាន់បានចុះឈ្មោះ និងមិនទាន់មានឈ្មោះបោះឆ្នោតនូវឡើយ។ កត្តាដែលនាំឱ្យមានស្ថិតិអ្នកចុះឈ្មោះមានចំនួនតិចនេះ បានកើតចេញពីចំណុចរួមផ្សំមួយចំនួនដូចជា ស្ថានភាពនយោបាយក្រោយការរំលាយគណបក្សសង្គ្រោះជាតិ ដែលពីមុនពួកគេចូលរួមសកម្មក្នុងការកៀងគរ និងការអប់រំប្រជាពលរដ្ឋក្នុងដំណើរការចុះឈ្មោះបោះឆ្នោត។ ចំណុចមួយទៀតគឺខ្វះយន្តការក្នុងការរៀបចំឱ្យមានការចុះឈ្មោះប្រជាពលរដ្ឋដែលបានចំណាកស្រុកនៅក្នុង និងក្រៅប្រទេសដែលមានចំនួនច្រើន។

ការសិក្សាពីគុណភាពនៃបញ្ជីឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ខុមហ្វ្រែលសង្កេតឃើញថា គុណភាពនៃបញ្ជីមានការពង្រឹងជារៀងរាល់ឆ្នាំ បើប្រៀបធៀបជាមួយឆ្នាំ២០១៦ ទាំងឈ្មោះស្ទួន ទាំងភាពមិនប្រក្រតីដែលកើតឡើងលើបញ្ជីឈ្មោះបោះឆ្នោត។

ខុមហ្វ្រែល នូវតែខិតខំសិក្សា និងរៀបចំផ្តល់ជាអនុសាសន៍ ទាក់ទងនីតិវិធី និងច្បាប់ចុះឈ្មោះបោះឆ្នោត រួមទាំងបញ្ហាដែលបានជួបប្រទះ ឬភាពមិនប្រក្រតីដែលបានកើតឡើងនៅក្នុងបញ្ជីឈ្មោះបោះឆ្នោត។

# សង្ខេបការរកឃើញ

**១. ការរៀបចំការចុះឈ្មោះបោះឆ្នោត៖** ដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត បានធ្វើឡើងជារៀងរាល់ឆ្នាំ។ ការចុះឈ្មោះឆ្នាំ២០១៩នេះ មានរយៈពេល ២២ថ្ងៃ សម្រាប់ចុះឈ្មោះជាមួយប្រជាពលរដ្ឋប៉ាន់ស្មាននៃអ្នកគ្រប់អាយុបោះឆ្នោតចំនួន ១០,១៧៨,៨០៩នាក់ និងការិយាល័យបោះឆ្នោតប៉ាន់ស្មានចំនួន ២៣,៣៦៤ ការិយាល័យ។ ដំណើរការចុះឈ្មោះបោះឆ្នោត មានក្រុមចុះឈ្មោះបោះឆ្នោត ចំនួន ១៦៤៦ក្រុម។ ទោះជាយ៉ាងណាប្រជាពលរដ្ឋចំណាកស្រុកនៅតែមិនអាចទទួលបានការសម្របសម្រួលឱ្យមានការចុះឈ្មោះនៅក្រៅប្រទេសនូវឡើយ។

**២. ការបង្កើតការិយាល័យបោះឆ្នោត និងស្ថិតិប្រជាពលរដ្ឋក្នុងការចុះឈ្មោះបោះឆ្នោត៖** ការិយាល័យបោះឆ្នោតត្រូវបានបង្កើតឡើងបន្ថែមជារៀងរាល់ឆ្នាំ។ ក្នុងឆ្នាំ២០១៩ គ.ជ.ប បានបង្កើតការិយាល័យបន្ថែម ៧១ លើការិយាល័យដែលមានស្រាប់ក្នុងឆ្នាំ២០១៨។ ក្នុងចំណោមអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩ គ.ជ.ប បានប៉ាន់ស្មានអ្នកចុះឈ្មោះថ្មីសម្រាប់ឆ្នាំ២០១៩ ចំនួនប្រមាណ ៣៧២,៦២៨នាក់។ ថ្ងៃដែលមានប្រជាពលរដ្ឋទៅចុះឈ្មោះបោះឆ្នោតច្រើនជាងគេ ខុមហ្វ្រែល សង្កេតឃើញកើតមានក្នុងពេលបុណ្យចំរើនព្រះជន្មព្រះករុណាព្រះបាទ សម្តេចព្រះបរមនាថ នរោត្តមសីហមុនី (ថ្ងៃទី១២ ដល់ថ្ងៃទី១៥ ខែឧសភា)។ ស្ថិតិប្រជាពលរដ្ឋក្នុងការចុះឈ្មោះតាមរាជធានីខេត្ត មានចំនួនខុសគ្នា ក្នុងនោះខេត្តចំនួន ៤ ដូចជាខេត្តស្វាយរៀង ខេត្តតាកែវ ប៉ៃលិន និងត្បូងឃ្មុំ មានចំនួនអ្នកចុះឈ្មោះថ្មីពី ៥០ភាគរយឡើងទៅនៃស្ថិតិប៉ាន់ស្មានអ្នកចុះឈ្មោះបោះឆ្នោតថ្មីឆ្នាំ២០១៩ ក្រៅពីនោះមានចំនួនតិចជាង ៥០ភាគរយ។

តួលេខនៃអ្នកចុះឈ្មោះបោះឆ្នោតថ្មីចេញទៅចុះឈ្មោះមានតួលេខទាប ដោយលទ្ធផលផ្លូវការនៃអ្នកចុះឈ្មោះបោះឆ្នោតបានបង្ហាញថា អ្នកចុះឈ្មោះបោះឆ្នោតថ្មីចុះបានចំនួន ១០៨,២៧២នាក់ស្មើនឹង ២៨.៩៩ភាគរយ នៃស្ថិតិប៉ាន់ស្មានចុះថ្មី។ ជាមួយការចុះឈ្មោះនេះ ខុមហ្វ្រែល មិនអាចស្នើសុំតួលេខនៃការចំណាយថវិកាសម្រាប់ការចុះឈ្មោះនេះបាននូវឡើយទេ។ ខុមហ្វ្រែល នឹងរីករាយស្វែងរកជម្រើសនៃវិធីសាស្ត្រសម្រាប់ពង្រឹងប្រសិទ្ធិភាពក្នុងការចំណាយដើម្បីជួយថវិកាជាតិ បើសិនជា ខុមហ្វ្រែលទទួលបានព័ត៌មានគ្រាប់គ្រាន់ពីការចំណាយប្រចាំឆ្នាំនេះ។

**៣. ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩៖** ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ខុមហ្វ្រែល បានរកឃើញថា ក្នុងចំណោមឈ្មោះអ្នកបោះឆ្នោតមានក្នុងបញ្ជីចំនួន ៨,៦២៩,៣៥៧ឈ្មោះ មានឈ្មោះ ៤៤ឈ្មោះ នៅក្នុងបញ្ជីឈ្មោះបោះឆ្នោត ដែលមានទិន្នន័យដូចគ្នា។ ឈ្មោះដូចគ្នានេះ (ស្ទួន) បើប្រៀបធៀបជាមួយឆ្នាំ២០១៨ ឃើញថាមានតួលេខថយចុះ (ចំនួនឈ្មោះស្ទួនមានចំនួន ៨៩ឈ្មោះ កាលឆ្នាំ ២០១៨)។ ខុមហ្វ្រែលបានកត់សំគាល់ឃើញថា ឈ្មោះស្ទួនដែលបានកើតឡើងក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០១៨ ចំនួន ៨៩ឈ្មោះនោះ ធ្លាប់បានបញ្ជូនឈ្មោះទាំងនោះទៅ គ.ជ.ប ដើម្បីដោះស្រាយ តែស្ទួននេះ នូវតែបន្តមានវត្តមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ចំនួន ២៦ឈ្មោះដដែល។ **ខុមហ្វ្រែល នូវតែបន្តការពិភាក្សាជាមួយស្ថាប័ន គ.ជ.ប ពីហេតុផលនៃឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតស្ទួនក្នុងបញ្ជីឈ្មោះនេះ។** តាមរយៈការសិក្សាលើអត្តសញ្ញាណសម្រាប់ចុះឈ្មោះបោះឆ្នោត (អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ-អ.ខ ឬ ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត-ឯ.អ) នៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ដែលមានឈ្មោះសរុប ៨.៦លានឈ្មោះ បានបង្ហាញថា លេខ អ.ខ ឬលេខ ឯ.អ ដូចគ្នា ឬស្ទួន (យ៉ាងតិច២ឈ្មោះ)

រកឃើញមានចំនួនសរុប ២៦,១៦០ឈ្មោះ។ ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតចំនួន ៨,៦២៩,៣៥៧ ឈ្មោះ អ្នកប្រើប្រាស់ឯកសារ អ.ខ សរុបចំនួន ៨,១៩៦,០៣៤ (៩៥ភាគរយ)ឈ្មោះ និងអ្នកប្រើប្រាស់ ឯ.អ សរុបចំនួន ៤៣៣,៣២៣ (៥ភាគរយ)ឈ្មោះ។ ក្នុងចំណោមអ្នកប្រើប្រាស់ អ.ខ ចំនួន ៨,១៩៦,០៣៤ មានអ្នកប្រើប្រាស់ អ.ខ ប្រភេទទី១ ចំនួន ៦០៨,៦៤១ (៧.៤ភារយ)ឈ្មោះ ប្រភេទទី២ ចំនួន ៣៤២,៩៥១(៤.២ ភាគរយ) និងប្រភេទទី៣ មានចំនួន ៧,២៤៤,៤៤២ (៨៨.៤ភាគរយ) ឈ្មោះ។

## អនុសាសន៍សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត

យោងតាមការសង្កេតលើដំណើរការនៃការចុះឈ្មោះបោះឆ្នោតចាប់ពីឆ្នាំ២០១៦ រហូតឆ្នាំ ២០១៩ និងការសិក្សាលើបញ្ជីឈ្មោះបោះឆ្នោត រួមទាំងបញ្ហាដែលកើតមានចំពោះបញ្ជីឈ្មោះបោះឆ្នោតខុមហ្វ្រែល សូមជូននូវអនុសាសន៍មួយចំនួន ដូចខាងក្រោម៖

- ស្ថាប័ន គ.ជ.ប ខិតខំបន្ថែម និងបន្តជជែកជាមួយរដ្ឋសភា ដើម្បីធ្វើវិសោធនកម្មច្បាប់បោះឆ្នោត ឬបង្កើតនីតិវិធីបើកផ្លូវឱ្យមានយន្តការចុះឈ្មោះប្រជាពលរដ្ឋចំណាកស្រុកនៅក្រៅប្រទេសដែលមិនទាន់បានចុះឈ្មោះ ឱ្យមានលទ្ធភាពបានចុះឈ្មោះនៅខាងក្រៅប្រទេស។
- គ.ជ.ប ត្រូវធ្វើការសិក្សាជាមួយក្រសួងមហាផ្ទៃ ធ្វើយ៉ាងណាបង្កើនការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្នា ជាពិសេសអ្នកបោះឆ្នោតដែលប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត (ឯ.អ)។
- គ.ជ.ប ត្រូវតែផ្តល់ឈ្មោះប្រជាពលរដ្ឋអ្នកបោះឆ្នោតដែលបានប្រើ អ.ខ ប្រភេទទី១ និងប្រភេទទី២ ដែលអស់សុពលភាពមាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោត និងជម្រុញអ្នកបោះឆ្នោតឱ្យធ្វើការកែតម្រូវព័ត៌មានជាមួយឯកសារដែលគាត់មានជាក់ស្តែង រួមទាំងជំម្រុញទៅក្រសួងមហាផ្ទៃ ដើម្បីឱ្យមានការប្តូរ អ.ខ ប្រភេទទី១ ឬទី២ ដែលអស់សុពលភាព ជូនដល់ប្រជាពលរដ្ឋប្រើប្រាស់។
- ពង្រឹងការយកចិត្តទុកដាក់របស់មន្ត្រីការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងការបំពេញឯកសារ ឬការផ្លាស់ប្តូរព័ត៌មានដែលអ្នកបោះឆ្នោតបានស្នើសុំ ដើម្បីកាត់បន្ថយកំហុសបច្ចេកទេសឱ្យមកកម្រិតទាបបំផុត ដែលធ្វើបាន។
- លេខអត្តសញ្ញាណប័ណ្ណដែលមិនច្បាស់លាស់ពេលថតបញ្ជូនមក គ.ជ.ប គួរតែបង្ហាញទៅក្រុមប្រឹក្សាឃុំសង្កាត់ ឬស្មៀនឃុំស្រាវជ្រាវ និងផ្ទៀងផ្ទាត់ រួចប្រគល់ឱ្យមន្ត្រីក្នុងការិយាល័យចុះឈ្មោះ ធ្វើការផ្ទៀងផ្ទាត់ឡើងវិញ ពេលចុះលើកក្រោយៗទៀត

# ការសង្កេត និងការធ្វើសវនកម្ម

## ក. ការរៀបចំដំណើរការចុះឈ្មោះបោះឆ្នោត

ដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ដែលមិនស្ថិតនៅក្នុងឆ្នាំបោះឆ្នោត គ.ជ.ប បានកំណត់កាលបរិច្ឆេទនៃការចុះឈ្មោះ នៅក្នុងខែឧសភាវិញ។ រយៈពេលនៃការចុះឈ្មោះបោះឆ្នោតមានចំនួន ២២ថ្ងៃ គឺចាប់ពីថ្ងៃទី១ ដល់ ២២ ខែឧសភា ឆ្នាំ២០១៩។

គ.ជ.ប បានធ្វើការប៉ាន់ប្រមាណស្ថិតិប្រជាពលរដ្ឋសរុប សម្រាប់ការចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ ២០១៩នេះ ចាប់ពីអាយុ១៨ឆ្នាំឡើង (អ្នកបានកើតមុន ឬត្រឹមថ្ងៃទី១ ខែឧសភា ឆ្នាំ២០០១ ប្រមាណចំនួន ១០,១៧៨,៨០៩នាក់ ក្នុងនោះស្ថិតិប៉ាន់ប្រមាណអ្នកចុះឈ្មោះបោះឆ្នោតថ្មី មានចំនួន ៣៧២,៦២៨នាក់ និង ការិយាល័យប៉ាន់ប្រមាណចំនួន ២៣,៣៦៤។

ជាមួយដំណើរការចុះឈ្មោះបោះឆ្នោតនេះ គ.ជ.ប ក៏នូវតែផ្តល់សេវាចុះឈ្មោះបោះឆ្នោត នៅតាមឃុំ សង្កាត់ និងនៅតាមភូមិ។ ក្នុងរយៈពេល២២ថ្ងៃនេះ គ.ជ.ប បានកំណត់ផែនការនៃការចុះឈ្មោះបោះឆ្នោតគឺ ៦ថ្ងៃដំបូង ចុះឈ្មោះបោះឆ្នោតនៅសាលាឃុំសង្កាត់ ហើយ៧ថ្ងៃ ចុះឈ្មោះបោះឆ្នោតនៅតាមភូមិមួយចំនួន ក្នុងឃុំ សង្កាត់ និង៤ថ្ងៃចុងក្រោយត្រឡប់មកចុះឈ្មោះនៅតាមសាលាឃុំ សង្កាត់វិញ។

### ក.១ ការរៀបចំប្រតិទិនដំណើរការចុះឈ្មោះបោះឆ្នោត

ប្រតិទិននៃដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩នេះ បានរៀបចំមានរយៈពេល ២២ថ្ងៃ (ចាប់ពីថ្ងៃទី១ ដល់ទី២២ ខែឧសភា ឆ្នាំ២០១៩)។

នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៩ គ.ជ.ប បានបិទផ្សាយបញ្ជីឈ្មោះដំបូង និងបញ្ជីឈ្មោះត្រូវលុបចេញ ពីបញ្ជីឈ្មោះបោះឆ្នោតឃុំសង្កាត់ ទូទាំងប្រទេស។ ចាប់ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ គ.ជ.ប បានប្រកាសសុពលភាព និងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ និងបង្ហោះលើគេហទំព័ររបស់ គ.ជ.ប (www.voterlist.org.kh) ។

ចាប់ពីថ្ងៃទី២៨ ខែឧសភា ជាថ្ងៃចុងក្រោយនៃការដោះស្រាយប្តឹងតវ៉ា ដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ថ្ងៃទី៨ ខែមិថុនា ថ្ងៃចុងក្រោយនៃការដោះស្រាយបណ្តឹងតវ៉ាដោយ គ.ជ.ប។ ថ្ងៃទី២៤ ខែមិថុនា ថ្ងៃចុងក្រោយនៃការដោះស្រាយបណ្តឹងតវ៉ាដោយក្រុមប្រឹក្សាធម្មនុញ្ញ។

គ.ជ.ប បានធ្វើការជ្រើសរើសមន្ត្រីសំរាប់ដំណើរការចុះឈ្មោះបោះឆ្នោតក្នុង ១៦៤៦ឃុំសង្កាត់។

# ខ. ការបង្កើតការិយាល័យបោះឆ្នោត និងស្ថិតិប្រជាពលរដ្ឋក្នុងការចុះឈ្មោះបោះឆ្នោត

## ខ.១ ស្ថិតិនៃការប៉ាន់ស្មានរបស់ គ.ជ.ប

កំណែទម្រង់ការចុះឈ្មោះបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោតត្រូវបានធ្វើវិសោធនកម្មច្បាប់ឡើងវិញ ក្រោយពីមានកិច្ចព្រមព្រៀងផ្នែកនយោបាយក្រោយការបោះឆ្នោតឆ្នាំ២០១៣។ ការចុះឈ្មោះបោះឆ្នោតថ្មី បានចាប់ផ្តើមចុះឡើងវិញក្នុងឆ្នាំ២០១៦ ដោយប្រើប្រាស់ប្រព័ន្ធជីវមាត្រ និងថតរូប។

**ក្រាហ្វិកទី១ ស្ថិតិប៉ាន់ស្មានអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោត និងប៉ាន់ស្មានចុះថ្មី**




តាមក្រាហ្វិកទី១ ខាងលើបានបង្ហាញថា ឆ្នាំ២០១៦ គឺជាឆ្នាំដែលចុះឈ្មោះថ្មីឡើងវិញទាំងអស់ ដើម្បីរៀបចំបញ្ជីឈ្មោះបោះឆ្នោតថ្មី។ ឆ្នាំដែលចុះឈ្មោះដំបូងនេះ គ.ជ.ប បានចេញស្ថិតិផ្លូវការជាមួយអ្នកបានចុះឈ្មោះបោះឆ្នោតចំនួន ៩,៦៦៤,២១៦នាក់។ ក្នុងឆ្នាំ២០១៧ គ.ជ.ប បានប៉ាន់**ស្មាន**អ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតថ្មីប្រមាណចំនួនជាង ៩,៨លាននាក់ តែក្នុងចំណោមនោះ អ្នកចុះឈ្មោះថ្មីមានចំនួនជា ១,៦លាននាក់។ ក្នុងឆ្នាំ២០១៨ ស្ថិតិប៉ាន់**ស្មាន**មានចំនួនជាង ៩,៩លាននាក់ រីឯស្ថិតិប៉ាន់**ស្មាន**ចុះឈ្មោះថ្មីមានតែចំនួនជាង ៤៨ម៉ឺននាក់។ រហូតមកដល់ឆ្នាំ២០១៩ ស្ថិតិចុះឈ្មោះកើនឡើងជាង ១០,១លាននាក់ តែស្ថិតិប៉ាន់**ស្មាន**ចុះថ្មីធ្លាក់ត្រឹមតែ ៣៧,២ម៉ឺននាក់។

## ខ.២ ការបង្កើតការិយាល័យបោះឆ្នោត

ក្នុងដំណើរការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ការិយាល័យបោះឆ្នោតត្រូវបានបង្កើតបន្ថែមថ្មីដោយការប៉ាន់**ស្មាន**ចំនួន ២៣,៣៦៤ការិយាល័យ។ ក្រោយពីចុះឈ្មោះបោះឆ្នោតត្រូវបានបញ្ចប់ ការិយាល័យបោះឆ្នោតដែល គ.ជ.ប បានប្រើប្រាស់ជាផ្លូវការមានចំនួន ២៣,៣៦៤ការិយាល័យ ដែលការិយាល័យនេះបានបន្ថែមចំនួន ៧១ការិយាល័យលើការិយាល័យផ្លូវការឆ្នាំ២០១៨។

## ក្រាហ្វិកទី២ ចំនួនការិយាល័យបោះឆ្នោតប្រើប្រាស់ចាប់ពីឆ្នាំ២០១៦ ដល់២០១៩




## ខ.៣ ស្ថិតិប្រជាពលរដ្ឋក្នុងការចុះឈ្មោះបោះឆ្នោត

លទ្ធផល ប៉ាន់ស្មានបណ្តោះអាសន្ននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩ គ.ជ.ប បានធ្វើការប៉ាន់ស្មានអ្នកមានសិទ្ធិចុះឈ្មោះបោះឆ្នោតប្រមាណ ១០,១៧៨,៨០៩នាក់។ ក្នុងចំណោមតួលេខដែល គ.ជ.ប បានប៉ាន់ស្មាននេះ តួលេខនៃការចុះឈ្មោះថ្មីសម្រាប់ឆ្នាំ២០១៩ ប្រមាណ ៣៧២,៦២៨នាក់។

## ក្រាហ្វិកទី៣ ទិន្នន័យការចុះឈ្មោះបោះឆ្នោតជាប្រចាំថ្ងៃ



លទ្ធផលក្នុងក្រាហ្វិកទី៣ ខាងលើនេះបានបង្ហាញថា ចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ប្រជាពលរដ្ឋដែលគ្រប់អាយុមកចុះឈ្មោះបោះឆ្នោត មានចំនួនជាមធ្យមប្រហែល ៥ពាន់នាក់ក្នុងមួយថ្ងៃ។ នៅថ្ងៃដំបូងមានប្រជាពលរដ្ឋមកចុះឈ្មោះចំនួន ៣,៩៣៩នាក់។ តួលេខនៃការចុះឈ្មោះ បានកើនឡើងមានចំនួនតិចតួច ចាប់ពីថ្ងៃទី០៥ ដល់ថ្ងៃទី១៥ ខែឧសភា ក្នុងរង្វង់ចំនួនពី ៤ពាន់នាក់ ទៅជាង ៧ពាន់នាក់ក្នុងមួយថ្ងៃ។ តួលេខនេះបន្តធ្លាក់ចុះប្រហែលជា ២ពាន់នាក់ បន្តធ្លាក់ចុះចាប់ពីថ្ងៃទី១៦ ខែឧសភា។

## ខ.៣.១ ការប្រៀបធៀបតួលេខនៃការចុះឈ្មោះបោះឆ្នោត




តួលេខក្នុងការចុះឈ្មោះបោះឆ្នោត ផ្អែកតាមស្ថិតិប៉ាន់ស្មានរបស់ គ.ជ.ប ក្នុងឆ្នាំនិមួយៗ និងរាជធានី ខេត្តនីមួយៗ។ តួលេខផ្លូវការឆ្នាំ២០១៩ បង្ហាញថា គ.ជ.ប ចុះឈ្មោះបានចំនួន ៨៤.៧៨ ភាគរយ នៃស្ថិតិប៉ាន់ស្មានចំនួន ១០,១៧៨,៨០៩នាក់។

ស្ថិតិប៉ាន់ស្មាននោះ មានអ្នកប៉ាន់ស្មានចុះឈ្មោះថ្មីចំនួន ៣៧២,៦២៨នាក់។ លទ្ធផលជាផ្លូវការក្រោយការចុះឈ្មោះបោះឆ្នោត បានបង្ហាញថា អ្នកចុះឈ្មោះថ្មីចុះបានចំនួន ១០៨,២៧២នាក់ ស្មើនឹង ២៨.៩៩ភាគរយ នៃស្ថិតិប៉ាន់ស្មានចុះថ្មី។

## ក្រាហ្វិកទី៤ ភាគរយអ្នកបានចុះឈ្មោះបោះឆ្នោតតាមឆ្នាំ



ការធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោត បានធ្វើជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៧ រហូតមកដល់ឆ្នាំ២០១៩នេះ។ ក្រាហ្វិកទី៤ ខាងលើបានបង្ហាញថា ឆ្នាំ២០១៧ តួលេខប៉ាន់ស្មានអ្នកចុះឈ្មោះបោះឆ្នោតថ្មីមានចំនួន ១,៦២៦,២៥២នាក់ ជាក់ស្តែងអ្នកចុះថ្មីមានចំនួន ៤៤០,៣១០នាក់ ស្មើនឹង ២៧.០៨ភាគរយ។ ការប្រៀបធៀបគ្នារវាងឆ្នាំនីមួយៗ មានការពន្យល់ភាគរយខុសគ្នា ដូចជាក្នុងឆ្នាំ២០១៨ ស្ថិតិប៉ាន់ស្មានចុះឈ្មោះថ្មីចំនួន ៤៨៩,៩៦៣នាក់ទាបជាង ស្ថិតិឆ្នាំ២០១៧ រីឯអ្នកបានចុះឈ្មោះក្នុងឆ្នាំ២០១៨ បានចំនួន ១៩៥,៣៨៥នាក់ ទាបជាង បើធៀបជាមួយឆ្នាំ២០១៧។ សម្រាប់ឆ្នាំ២០១៩ ស្ថិតិប៉ាន់ស្មានរឹតតែទាបជាងឆ្នាំ២០១៨ តែបើមើលពីភាគរយវិញឃើញថាឆ្នាំ២០១៨ មានភាគរយនៃការចុះឈ្មោះថ្មីខ្ពស់ជាងឆ្នាំ២០១៧ និងឆ្នាំ២០១៩។

**ក្រាហ្វិកទី៥ តួលេខអ្នកបានចុះឈ្មោះបោះឆ្នោតថ្មីតាមរាជធានី ខេត្ត ធៀបតួលេខប៉ាន់ប្រមាណចុះថ្មី**




ក្រាហ្វិកទី៥ បានបង្ហាញពីស្ថិតិប៉ាន់ស្មានអ្នកចុះឈ្មោះថ្មីថា មានរាជធានីខេត្តចំនួន៤ គឺបន្ទាយមានជ័យ កំពត ភ្នំពេញ និងសៀមរាប មានស្ថិតិប៉ាន់ស្មានចុះថ្មីលើសពី៣ម៉ឺននាក់ ក្រៅពីនោះ គ.ជ.ប បានប៉ាន់ស្មានចុះថ្មីក្រោម ៣ម៉ឺននាក់។ ទោះជាយ៉ាងណា បើពិនិត្យលើភាគរយនៃអ្នកចុះឈ្មោះបោះឆ្នោតថ្មី ធៀបជាមួយស្ថិតិប៉ាន់ស្មាន មានខេត្តចំនួន៤ មានអ្នកចុះឈ្មោះថ្មីលើសពី ៥០ភាគរយ ដូចជាខេត្តស្វាយរៀង មាន ៩៣.៧ភាគរយ ខេត្តប៉ៃលិន ៦៧.២ភាគរយ ខេត្តតាកែវ ៦៥ភាគរយ និងខេត្តត្បូងឃ្មុំ ៦០.២ភាគរយ។

### ខ.៣.២ ស្ថិតិនៃការប៉ាន់ប្រមាណ និងតួលេខក្រោយការចុះឈ្មោះរបស់ គ.ជ.ប ប្រចាំឆ្នាំ

ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ អត្រាអ្នកចុះឈ្មោះបោះឆ្នោតមានចំនួនក្រោម ៩០ភាគរយ។ ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ អត្រាកំណើននៃការចុះឈ្មោះស្ថិតក្នុងកំណើន ឬធ្លាក់ចុះប្រហែល ២ភាគរយប្រចាំឆ្នាំ។ ចាប់តាំងពីដំណើរការចុះឈ្មោះតាមប្រព័ន្ធកុំព្យូទ័រ(ឆ្នាំ២០១៦)មក បញ្ជីឈ្មោះបោះឆ្នោតបានទទួលការ

គាំទ្រ និងជឿជាក់ជាច្រើនពីភាគីពាក់ព័ន្ធ។ ជាពិសេសខុមហ្វ្រែល សង្កេតឃើញថា មិនមានគណបក្សនយោបាយណាមួយ តវ៉ាជាលាយលក្ខអក្សរ ឬចោទប្រកាន់ថាបញ្ជីឈ្មោះមិនមានគុណភាពនោះឡើយ។

**ក្រាហ្វិកទី៦ ភាគរយនៃអ្នកបានចុះឈ្មោះបោះឆ្នោតចាប់ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០១៨**




ក្រាហ្វិកទី៦ បង្ហាញថា ទិន្នន័យ និងអត្រានៃការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ធៀបជាមួយស្ថិតិនៃការប៉ាន់ប្រមាណប្រចាំឆ្នាំរបស់ គ.ជ.ប ចាប់តាំងពីឆ្នាំ១៩៩៣ រហូតឆ្នាំ២០១៨។ ក្នុងឆ្នាំ១៩៩៣ ការចុះឈ្មោះបោះឆ្នោត បានកើនឡើងលើសពីស្ថិតិប៉ាន់ស្មាន២ភាគរយ។ ស្ថិតិនៃការប៉ាន់ស្មាននេះ បន្តធ្លាក់ចុះក្នុងឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០២ ជាមួយចំនួននៃអ្នកចុះឈ្មោះ ៨៣ភាគរយ ធៀបជាមួយស្ថិតិប៉ាន់ប្រមាណ ។ ការចុះឈ្មោះបោះឆ្នោតបានកើនឡើងលើសពី១០០ភាគរយ បើធៀបជាមួយស្ថិតិប៉ាន់ស្មានចាប់ពីឆ្នាំ២០០៣ ឆ្នាំ២០០៧ ឆ្នាំ២០០៨ ឆ្នាំ២០១២ និងឆ្នាំ២០១៣។ ប្រព័ន្ធចុះឈ្មោះបោះឆ្នោតដែលប្រើប្រាស់ក្នុងការចុះឈ្មោះ មុនឆ្នាំ២០១៦ គឺមិនបានប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ និងរៀបចំក្រុមចុះឈ្មោះដូចពេលបច្ចុប្បន្ននេះទេ ហេតុនេះកម្រិតនៃការត្រួតពិនិត្យភាពត្រឹមត្រូវអាចទទួលរងបញ្ហាជាច្រើន ដូចជាឈ្មោះស្ទួន ការប្រើប្រាស់ឯកសារជាន់គ្នា និងការបាត់បង់ឈ្មោះពីក្នុងបញ្ជី។

កំណើននៃការប៉ាន់ស្មានចុះឈ្មោះប្រចាំឆ្នាំ ចាប់ពីឆ្នាំ២០១៦ មកដល់២០១៩ មានការកើនឡើងជាលំដាប់ពី ៩,៦លាននាក់ មកដល់ ១០,១លាននាក់។ រីឯអ្នកបានចុះឈ្មោះបោះឆ្នោតក៏បានកើនឡើងពី៨,៣លាននាក់ មកដល់ ៨,៦លាននាក់ គិតត្រឹមឆ្នាំ២០១៩។

ទោះបីចំនួននៃស្ថិតិប៉ាន់ស្មាន និងអ្នកបានចុះឈ្មោះបោះឆ្នោត មានការកើនឡើងយ៉ាងណាក៏ដោយ តែខុមហ្វ្រែលបានសង្កេតឃើញថា ភាគរយនៃអ្នកបានចុះឈ្មោះបោះឆ្នោត មិនមានកំណើនដូចតួលេខនោះ

ទេ គឺឆ្នាំ២០១៧ មានអ្នកចុះឈ្មោះបាន ៨៤.៨ភាគរយ ក្នុងឆ្នាំ២០១៨ មានអ្នកចុះឈ្មោះកើនឡើង ៨៦.២ ភាគរយ តែមកដល់ឆ្នាំ២០១៩ មានភាគរយធ្លាក់ចុះត្រឹម ៨៤.៧៨ភាគរយ ប្រហែលឆ្នាំ២០១៧។

# គ. បរិយាកាសទូទៅទាក់ទងការចុះឈ្មោះបោះឆ្នោត

## គ.១ ទីតាំងចុះឈ្មោះបោះឆ្នោត

សាលាឃុំសង្កាត់គឺជាទីតាំងការិយាល័យចុះឈ្មោះបោះឆ្នោតគោលនៅក្នុងឃុំសង្កាត់នីមួយៗ។ ក្រៅពីទីតាំងនៅសាលាឃុំសង្កាត់ នៅតាមភូមិមួយចំនួន ដែលជាទីតាំងរដ្ឋបាល និងសន្តិសុខ ងាយក្នុងការផ្គត់ផ្គង់ចរន្តអគ្គិសនី ដែលត្រូវមានបរិវេណខាងក្នុង បរិវេណខាងក្រៅ *(យោងតាមបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ប្រការ៤.៥)*។ មិនខុសពីសព្វមួយដង ការចុះឈ្មោះបោះឆ្នោត ខុមហ្វ្រែលបានសង្កេតឃើញមានការចុះឈ្មោះបោះឆ្នោតនៅតាមភូមិផងដែរ ទោះបីមិនបានគ្រប់ភូមិក្នុងឃុំសង្កាត់ក៏ដោយ។

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩ នេះ ត្រូវបែងចែកពេលវេលា ដូចខាងក្រោម៖

- រយៈពេល ៦ថ្ងៃ ពីថ្ងៃទី១ ដល់ថ្ងៃទី៦ ខែឧសភា ចុះឈ្មោះនៅតាមសាលាឃុំសង្កាត់
- រយៈពេល ១១ថ្ងៃ ពីថ្ងៃទី៧ ដល់ថ្ងៃទី១៧ ខែឧសភា ចុះឈ្មោះចល័តនៅតាមភូមិមួយចំនួនក្នុងឃុំសង្កាត់
- និងរយៈពេល ៥ថ្ងៃ ពីថ្ងៃទី១៨ ដល់ថ្ងៃទី២២ ខែឧសភា ត្រឡប់មកចុះឈ្មោះនៅតាមសាលាឃុំសង្កាត់វិញ។

## រូបភាពទី១ ប្រតិទិនក្រុមចុះឈ្មោះបោះឆ្នោតតាមភូមិ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មការរៀបចំការបោះឆ្នោតខេត្ត កំពត
ក្រុមចុះឈ្មោះបោះឆ្នោតសង្កាត់អណ្ដូងខ្មែរ

ប្រតិទិន
ស្ដីពីការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩

| ល.រ | កាលបរិច្ឆេទ | ឈ្មោះទីតាំង | រយៈពេល | ផ្សេងៗ |
|---|---|---|---|---|
| ១ | ០១/០៥/២០១៩→០៦/០៥/២០១៩ | សាលាសង្កាត់ | ៦ ថ្ងៃ | |
| ២ | ០៧/០៥/២០១៩→០៨/០៥/២០១៩ | ភូមិ ទ្វីខាងត្បូង | ២ ថ្ងៃ | |
| ៣ | ០៩/០៥/២០១៩→១០/០៥/២០១៩ | ភូមិ ទ្វីខាងជើង | ២ ថ្ងៃ | |
| ៤ | ១១/០៥/២០១៩→១២/០៥/២០១៩ | ភូមិ អូរតូច | ២ ថ្ងៃ | |
| ៥ | ១៣/០៥/២០១៩→១៤/០៥/២០១៩ | ភូមិ អណ្ដូងខ្មែរ | ២ ថ្ងៃ | |
| ៦ | ១៥/០៥/២០១៩→១៦/០៥/២០១៩ | ភូមិ តាដឹប | ២ ថ្ងៃ | |
| ៧ | ១៧/០៥/២០១៩→២២/០៥/២០១៩ | សាលាសង្កាត់ | ៦ ថ្ងៃ | |

ថ្ងៃ អង្គារ១១ រោច ខែ ចេត្រ ឆ្នាំ កុរឯកស័ក.ពស ២៥៦២
អណ្ដូងខ្មែរ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១៩
ប្រធានក្រុមចុះឈ្មោះបោះឆ្នោត



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកំពង់ឆ្នាំង
សាលាសង្កាត់ កំពង់ឆ្នាំង

ប្រតិទិននៃការចុះឈ្មោះបោះឆ្នោត
ចាប់ពីថ្ងៃទី០១ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩

| កាលបរិច្ឆេទ | ចំនួនថ្ងៃ | ភូមិ / សង្កាត់ | ទីកន្លែងចុះឈ្មោះបោះឆ្នោត |
|---|---|---|---|
| ០១.០៥.២០១៩ ដល់០៦.០៥.២០១៩ | ០៦ថ្ងៃ | សាលាសង្កាត់ | សាលាសង្កាត់ |
| ០៧.០៥.២០១៩ ដល់០៨.០៥.២០១៩ | ០២ថ្ងៃ | ភូមិឡឺកត្រី | ផ្ទះមេភូមិ លោកស្រីលឹម ចិន |
| ០៩.០៥.២០១៩ ដល់១០.០៥.២០១៩ | ០២ថ្ងៃ | ភូមិកណ្ដាល | សាលាបុណ្យភូមិកណ្ដាល |
| ១១.០៥.២០១៩ ដល់១២.០៥.២០១៩ | ០២ថ្ងៃ | ភូមិជំណាក់ពពូល | សាលាបុណ្យភូមិជំណាក់ពពូល |
| ១៣.០៥.២០១៩ ដល់១៤.០៥.២០១៩ | ០២ថ្ងៃ | ភូមិត្រពាំងចឹកសា | សាលាបុណ្យភូមិត្រពាំងចឹកសា |
| ១៥.០៥.២០១៩ ដល់១៦.០៥.២០១៩ | ០២ថ្ងៃ | ភូមិស្រែព្រីង | ផ្ទះលោកមេភូមិ ឡាច ចន្ធូថា |
| ១៧.០៥.២០១៩ | ០១ថ្ងៃ | ភូមិទួលក្រឡាញ់ | សាលាសង្កាត់ |
| ១៨.០៥.២០១៩ ដល់២២.០៥.២០១៩ | ០៥ថ្ងៃ | សាលាសង្កាត់ | សាលាសង្កាត់ |

ថ្ងៃពុធ ៥រោច ខែចេត្រ ឆ្នាំច សំរឹទ្ធស័ក ព ស ២៥៦២
ធ្វើនៅប្លេ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៩
ប្រធាន ក ច ប សង្កាត់កំពង់ឆ្នាំង
រ័ត្ន សុគន្ធ

បានឃើញ និងឯកភាព
ចៅសង្កាត់
កែវ_សុខវាត

រូបភាពទី១ ជាប្រតិទិននៃការចុះឈ្មោះបោះឆ្នោតនៅតាមភូមិ នៅក្នុងខេត្តកំពត ក្នុងសង្កាត់អណ្ដូងខ្មែរ និងប្រតិទិនចុះឈ្មោះក្នុងខេត្តកំពង់ឆ្នាំង ក្នុងសាលាសង្កាត់កំពង់ឆ្នាំង។

## រូបភាពទី២ ការិយាល័យចុះឈ្មោះបោះឆ្នោតនៅតាមភូមិ និងសាលាសង្កាត់






**ទីតាំងចុះឈ្មោះតាមភូមិនៅក្នុងខេត្តបន្ទាយមានជ័យ   ទីតាំងចុះឈ្មោះនៅសាលាសង្កាត់ក្នុងខេត្តកំពង់ចាម**

តាមរយៈការសង្កេតរបស់ ខុមហ្វ្រែល និងរូបភាពទី២ ខាងលើ បានបញ្ជាក់ថា ការចុះឈ្មោះនៅតាមភូមិ បានផ្ដល់លទ្ធភាពឱ្យប្រជាពលរដ្ឋដែលមានសិទ្ធិចុះឈ្មោះ ចូលរួមចុះឈ្មោះច្រើនជាងនៅសាលាឃុំសង្កាត់។

## គ.២ ការចូលរួមរបស់អង្គការសង្គមស៊ីវិល និងគណបក្សនយោបាយ

សកម្មភាពចូលរួមឃ្លាំមើលការចុះឈ្មោះអ្នកបោះឆ្នោតក្នុងឆ្នាំ២០១៩នេះ ខុមហ្វ្រែល បានសង្កេតឃើញថា ភាគីពាក់ព័ន្ធមិនបានចូលរួមយ៉ាងសកម្មដូចអំឡុងឆ្នាំ២០១៦នោះទេ ដូចជាភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍របស់អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។

ក្នុងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០១៩នេះ ខុមហ្វ្រែល មិនបានដាក់អ្នកសង្កេតការណ៍ចូលរួមឃ្លាំមើលដំណើរការចុះឈ្មោះបោះឆ្នោតនោះទេ តែខុមហ្វ្រែលបានឱ្យលេខាខេត្ត សរុបចំនួន ៨នាក់នៅ ៨ខេត្ត ដូចជា ខេត្តបន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពត កណ្តាល ព្រៃវែង រតនៈគិរី និងសៀមរាប ដើម្បីពិនិត្យមើលស្ថានភាពជាទូទៅនៃការចុះឈ្មោះ។

**រូបភាពទី៣ លេខាខេត្តខុមហ្វ្រែល ពិនិត្យមើលដំណើរការចុះឈ្មោះបោះឆ្នោត**




**ការឃ្លាំមើលការចុះឈ្មោះនៅខេត្តបន្ទាយមានជ័យ**



**ការឃ្លាំមើលការចុះឈ្មោះនៅខេត្តព្រៃវែង**



**ការឃ្លាំមើលការចុះឈ្មោះនៅខេត្តកំពត**

## ឃ. ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩

ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោត ខុមហ្វ្រែលបានធ្វើជារៀងរាល់ឆ្នាំចាប់តាំងពីឆ្នាំ២០១៦ រហូតមកដល់ឆ្នាំ២០១៩នេះ។ បញ្ជីឈ្មោះដែលត្រូវបានយកទៅធ្វើការសិក្សា ខុមហ្វ្រែលបានប្រើប្រាស់បញ្ជីឈ្មោះបោះឆ្នោតផ្លូវការឆ្នាំ២០១៩។

ការធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៩នេះ ខុមហ្វ្រែល បានផ្តោតលើចំណុចដែលត្រូវសិក្សា ដូចខាងក្រោម៖

- ការស្វែងរកវត្តមានអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោត និងភាពមិនប្រក្រតីនៃការចុះឈ្មោះបោះឆ្នោត
- ភាពមិនប្រក្រតីនៃឈ្មោះដូចគ្នា/ស្ទួនក្នុងបញ្ជីឈ្មោះបោះឆ្នោត
- ការប្រើប្រាស់ឯកសារសម្រាប់ចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីឈ្មោះបោះឆ្នោត
- ករណីសិក្សាជាមួយអ្នកមានឈ្មោះស្ទួនក្នុងបញ្ជីឈ្មោះបោះឆ្នោត

### ឃ.១ ការពិនិត្យទិន្នន័យ(ឈ្មោះដូចគ្នា) និងភាពមិនប្រក្រតីនៃបញ្ជីឈ្មោះបោះឆ្នោត

ការសិក្សាលើឈ្មោះផ្លូវការក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ក្នុងចំណោមឈ្មោះអ្នកមានសិទ្ធិបោះឆ្នោត ៨,៦២៩,៣៥៧នាក់ លទ្ធផលរកឃើញចំនួន ៤៤ឈ្មោះស្ទួន។ ឈ្មោះអ្នកមានសិទ្ធិបោះឆ្នោតដែលបានរកឃើញស្ទួនចំនួន៤៤ឈ្មោះ(មានក្នុងបញ្ជី) គឺស្មើនឹង អ្នកមានសិទ្ធិបោះឆ្នោត ចំនួន ២២នាក់។ **ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោត ដែលមានឈ្មោះស្ទួន មាន ១៣នាក់ជាអ្នកដែលមានឈ្មោះស្ទួនក្នុងខេត្ត និង៨នាក់ មានឈ្មោះស្ទួនក្រៅខេត្ត។ លទ្ធផលបានបង្ហាញទៀតថា** ក្នុងចំណោមអ្នកដែលមានឈ្មោះស្ទួនក្នុងខេត្ត គឺមានអ្នកមានសិទ្ធិបោះឆ្នោត ស្ទួនក្នុងឃុំសង្កាត់ចំនួន ៨នាក់ និងអ្នកដែលមានឈ្មោះស្ទួនក្នុងការិយាល័យ ចំនួន៤នាក់។

**ក្រាហ្វិកទី៧ ការប្រៀបធៀបឈ្មោះស្ទួនតាមឆ្នាំ**




លទ្ធផលនៃការរកឃើញ ដូចក្នុងក្រាហ្វិកទី៧ ខាងលើ បានបង្ហាញថាតួលេខស្ទួនក្នុងបញ្ជីឈ្មោះបោះឆ្នោតបានធ្លាក់ចុះនូវតួលេខស្ទួន ចាប់ពីឆ្នាំ២០១៧ មកដល់បច្ចុប្បន្ន បន្ទាប់ពីបញ្ជីឈ្មោះបោះឆ្នោតត្រូវបាន

កែសម្រួល។ ក្នុងឆ្នាំ២០១៧ លទ្ធផលដែលសិក្សាដោយអង្គការខុមហ្វ្រែល លើបញ្ជីឈ្មោះបោះឆ្នោត តាមរយៈឯកសារដើមពី គ.ជ.ប ជា ភីឌីអេស (PDF) រកឃើញឈ្មោះស្ទួន(ឈ្មោះដូចគ្នា) ចំនួន ៩៦១ឈ្មោះ ក្នុងឆ្នាំ ២០១៨ បានរកឃើញចំនួន ៨៩ឈ្មោះ និងឆ្នាំ២០១៩នេះ រកឃើញចំនួន ៤៤ឈ្មោះស្ទួន។

រូបភាពខាងក្រោម ជារូបភាពខ្លះៗ ក្រោយពីធ្វើការសិក្សាលើបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩ ដែលមានទិន្នន័យដូចគ្នា/ស្ទួន មានករណីដូចខាងក្រោមៈ

### រូបភាពទី៤ ទិន្នន័យអ្នកបោះឆ្នោតដែលមាន រូបភាពដូចគ្នា តែខុសខេត្ត

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ០២ ឈ្មោះខេត្ត: បាត់ដំបង កូដឃុំ: ០៩៦ ឈ្មោះឃុំ: តាក្រី
ឈ្មោះភូមិ: ផ្លូវប្រាំមួយ លេខកូដការិយាល័យ: ១៥៣៤ ឈ្មោះការិយាល័យ: បឋមសិក្សាសាមសិប

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៨ | 01-387-800 |  | កែវ គន្ធា<br>អ.ខ ទី3 : 061040111 | ស្រី | 01-07-1989 | ផ្ទះ 331 ក្រុម 22 |

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ២៥ ឈ្មោះខេត្ត: ត្បូងឃ្មុំ កូដឃុំ: ០២០ ឈ្មោះឃុំ: ចាន់មូល
ឈ្មោះភូមិ: ចាន់មូល លេខកូដការិយាល័យ: ០២៨៣ ឈ្មោះការិយាល័យ: សាលារៀនភូមិចាន់មូល

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៩ | 11-089-322 |  | កែវ គុន្ធា<br>អ.ខ ទី2 : 061040111 | ស្រី | 01-07-1989 | ភូមិ ចាន់មូល |

### រូបភាពទី៥ ទិន្នន័យអ្នកបោះឆ្នោតមានរូបភាពដូចគ្នា តែខុសឃុំគ្នា

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ២៥ ឈ្មោះខេត្ត: ត្បូងឃ្មុំ កូដឃុំ: ០៥៥ ឈ្មោះឃុំ: គរ
ឈ្មោះភូមិ: ទំនប់សែនជ័យ លេខកូដការិយាល័យ: ១០៦៤ ឈ្មោះការិយាល័យ: បឋមសិក្សាហ៊ុន សែនក្បាលអូរ

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ១៨០ | 11-446-516 |  | វ៉ាន់ ភួង<br>អ.ខ ទី3 : 250121408 | ស្រី | 06-03-1978 | ភូមិ ទំនប់សែនជ័យ |

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ២៥ ឈ្មោះខេត្ត: ត្បូងឃ្មុំ កូដឃុំ: ០៥៦ ឈ្មោះឃុំ: ល្វៀង
ឈ្មោះភូមិ: ភូមិ ៤-១៦ លេខកូដការិយាល័យ: ១០៦៨ ឈ្មោះការិយាល័យ: ភូមិ៤-១៦

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ១០៧ | 11-446-511 |  | វ៉ាន់ ភួង<br>អ.ខ ទី3 : 250121408 | ស្រី | 06-03-1978 | ភូមិ ភូមិ ៤-១៦ |

## រូបភាពទី៦ ទិន្នន័យអ្នកបោះឆ្នោតមានការិយាល័យដូចគ្នា តែរូបភាពខុសគ្នា

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: **២៩** ឈ្មោះខេត្ត: ត្បូងឃ្មុំ កូដឃុំ: **00៧** ឈ្មោះឃុំ: ត្រពាំងព្រីង

ឈ្មោះភូមិ: ស្រែប្រាំង លេខកូដការិយាល័យ: **០១១៦** ឈ្មោះការិយាល័យ: បឋមសិក្សាភូមិស្រែប្រាំង

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៤៦៩ | 11-000-818 |  | អ៊ិន សុខអេង<br>អ.ខ ទី3 : 060500546 | ប្រុស | 25-06-1979 | ភូមិ ស្រែប្រាំង |
| ☐ ៤៧០ | 11-000-968 |  | អ៊ិន សុខអេង<br>អ.ខ ទី1 : 060500546 | ប្រុស | 25-06-1979 | ភូមិ ស្រែប្រាំង |

ទំព័រទី ៤៧ នៃ ៤៩ គណ:កម្មាធិការជាតិរៀបចំការបោះឆ្នោត

## ឃ.២ ករណីសិក្សាលើឈ្មោះស្ទួន ជាមួយអ្នកបោះឆ្នោតនៅមូលដ្ឋាន

- ករណីអ្នកបោះឆ្នោតឈ្មោះ កែវ គន្ធា ភេទស្រី មានទិន្នន័យទាំងអស់ស្មើរតែដូចគ្នា ខុសតែទីតាំងខេត្តពីរផ្សេងគ្នា។

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: **០២** ឈ្មោះខេត្ត: បាត់ដំបង កូដឃុំ: **០៩៦** ឈ្មោះឃុំ: តាក្រី

ឈ្មោះភូមិ: ផ្លូវប្រាំមួយ លេខកូដការិយាល័យ: **១៩៣៤** ឈ្មោះការិយាល័យ: បឋមសិក្សាសាមសិប

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៨ | 01-387-800 |  | កែវ គន្ធា<br>អ.ខ ទី3 : 061040111 | ស្រី | 01-07-1989 | ផ្ទះ 331 ក្រុម 22 |

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: **២៩** ឈ្មោះខេត្ត: ត្បូងឃ្មុំ កូដឃុំ: **០២០** ឈ្មោះឃុំ: ចាន់មូល

ឈ្មោះភូមិ: ចាន់មូល លេខកូដការិយាល័យ: **០២៨៣** ឈ្មោះការិយាល័យ: សាលារៀនភូមិចាន់មូល

| | | | | | | |
|---|---|---|---|---|---|---|
| ☐ ៩ | 11-089-322 |  | កែវ គុន្ធា<br>អ.ខ ទី2 : 061040111 | ស្រី | 01-07-1989 | ភូមិ ចាន់មូល |

- ករណី អ្នកបោះឆ្នោតឈ្មោះ ច្រឹក ជា ភេទស្រី មានទិន្នន័យស្មើរតែដូចគ្នា លើកលែងតែរូបថតប្រហាក់ប្រហែលគ្នា និងស្ថិតនៅក្នុងខេត្តពីរផ្សេងគ្នា។

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ០៨ ឈ្មោះខេត្ត: កណ្តាល កូដឃុំ: ០៨៣ ឈ្មោះឃុំ: សំបួរ
ឈ្មោះភូមិ: ព្រែកចារ លេខកូដការិយាល័យ: ០៨៨៦ ឈ្មោះការិយាល័យ: បឋមសិក្សាព្រែកចារ (ត្បូង)

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐៤៨ | 04-804-043 |  | ច្រឹក ជា<br>អ.ខ ទី3 : 050147835 | ស្រី | 12-12-1980 | ភូមិ ព្រែកចារ |

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ១៤ ឈ្មោះខេត្ត: ព្រៃវែង កូដឃុំ: ០៧៨ ឈ្មោះឃុំ: បឹងដោល
ឈ្មោះភូមិ: អំពិល លេខកូដការិយាល័យ: ១២១០ ឈ្មោះការិយាល័យ: វត្តអំពិល

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐៦៦ | 07-754-062 |  | ច្រឹក ជា<br>អ.ខ ទី1 : 050147835 | ស្រី | 12-12-1980 | ភូមិ អំពិល |

- ករណីអ្នកបោះឆ្នោតឈ្មោះ ផុន ផល ភេទប្រុស មានទិន្នន័យស្ទើរតែដូចគ្នា រូបថតដូចគ្នា និងស្ថិតនៅក្នុងការិយាល័យតែមួយ។

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ០៨ ឈ្មោះខេត្ត: កណ្តាល កូដសង្កាត់: ១៣៨ ឈ្មោះសង្កាត់: ស្វាយរលំ
ឈ្មោះភូមិ: ភូមិលេខ ៥ លេខកូដការិយាល័យ: ១៩៨៨ ឈ្មោះការិយាល័យ: សាលារៀនដើមអង្កោល

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐២២១ | 05-137-788 |  | ផុន ផល<br>អ.ខ ទី3 : 020869633 | ប្រុស | 08-04-1994 | ភូមិ ភូមិលេខ ៥ |
| ☐២២២ | 05-137-793 |  | ផុន ផល<br>អ.ខ ទី2 : 020869633 | ប្រុស | 08-04-1994 | ភូមិ ភូមិលេខ ៥ |

**កំណត់សំគាល់៖**

*ខុមហ្វ្រែលបានកត់សម្គាល់ឃើញថា ឈ្មោះស្ទួនដែលបានកើតឡើងក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៨ ចំនួន ៨៩ឈ្មោះ និងធ្លាប់បានបញ្ជូនឈ្មោះទាំងនោះទៅ គ.ជ.ប ដើម្បីដោះស្រាយ នូវតែបន្តវត្តមានស្ទួននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ចំនួន ២៦ឈ្មោះដដែល។*

*ករណីឈ្មោះស្ទួនចាស់ដែល គ.ជ.ប មិនទាន់បានកែតម្រូវនោះ ខុមហ្វ្រែល សូមបង្ហាញករណីអ្នកបោះឆ្នោតមានឈ្មោះ អ៊ាន សុខអេង មានលេខ អ.ខ ០៦០៥០០៥៤៦ ស្ថិតនៅក្នុងខេត្តត្បូងឃ្មុំ ឃុំត្រពាំងព្រីង ក្នុងការិយាល័យ ០១១៦ ខុមហ្វ្រែលបានដាក់ក្នុងបញ្ជីឈ្មោះស្ទួនជូនទៅ គ.ជ.ប តែឈ្មោះនេះបានរក្សានៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ដដែល។*

## រូបភាពទី៧ ឈ្មោះស្ទួនដែលបានរកឃើញក្នុងឆ្នាំ២០១៨ និងនៅតែបន្តរកឃើញក្នុងឆ្នាំ២០១៩



បញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៨

កូដខេត្ត: ២៥ ឈ្មោះខេត្ត: ត្បូងឃ្មុំ កូដឃុំ: ០០៧ ឈ្មោះឃុំ: ត្រពាំងព្រីង

ឈ្មោះភូមិ: ស្រែប្រាំង លេខកូដការិយាល័យ: ០១១៦ ឈ្មោះការិយាល័យ: បឋមសិក្សាភូមិស្រែប្រាំង

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៤៦៨ | 11-000-968 | | អ៊ិន សុខអេង<br>អ.ខ ទី1 : 060500546 | ប្រុស | 25-06-1979 | ភូមិ ស្រែប្រាំង |
| ☐ ៤៦៩ | 11-000-818 | | អ៊ិន សុខអេង<br>អ.ខ ទី3 : 060500546 | ប្រុស | 25-06-1979 | ភូមិ ស្រែប្រាំង |

## ឃ.៣ លេខអត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត (អ.ខ/ឯ.អ) ដូចគ្នា/ស្ទួន

ចាប់តាំងពីក្រសួងមហាផ្ទៃបានឱ្យប្រជាពលរដ្ឋខ្មែរប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរ(អ.ខ)មកដល់បច្ចុប្បន្ន ក្រសួងមហាផ្ទៃបានចេញ អ.ខ នេះមាន ៣ប្រភេទ។ ក្នុងចំណោមទាំង ៣ប្រភេទ មានប្រភេទទី៣ បានកត់ត្រាទិន្នន័យទុកក្នុងកុំព្យូទ័រ ដូចជារូបថត ស្នាមក្រយៅដៃ និងព័ត៌មានចាំបាច់ផ្សេងៗទៀត។ អ.ខ ប្រភេទទី៣ នេះ មានលេខសំគាល់មិនដូចគ្នាទេ គឺប្រជាពលរដ្ឋ ១នាក់ មានលេខសម្គាល់តែមួយ។ អ.ខ ប្រភេទទី១ និងទី២ រាល់ទិន្នន័យមិនបានកត់ត្រាទុកក្នុងប្រព័ន្ធទិន្នន័យត្រឹមត្រូវដូច អ.ខ ប្រភេទទី៣នោះទេ ម្យ៉ាងទៀតលេខសម្គាល់អាចជាន់គ្នាបាន។

ក្នុងអំឡុងពេលបោះឆ្នោត ប្រជាពលរដ្ឋទាំងឡាយណាមិនមាន អ.ខ សម្រាប់យកទៅចុះឈ្មោះបោះឆ្នោត ពួកគេត្រូវមកធ្វើឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត (ឯ.អ) នៅសាលាឃុំសង្កាត់។

តាមរយៈការសិក្សាលើអត្តសញ្ញាណសម្រាប់ចុះឈ្មោះបោះឆ្នោត (ឯ.អ ឬអ.ខ) នៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ដែលមានឈ្មោះសរុប ៨.៦លានឈ្មោះ បានបង្ហាញថា លេខ អ.ខ ឬលេខ ឯ.អ ដូចគ្នា ឬស្ទួន(យ៉ាងតិច២ឈ្មោះ) រកឃើញមានចំនួនសរុប ២៦,១៦០ឈ្មោះ។

**រូបភាពទី៨ ការប្រៀបធៀបតួលេខនៃលេខសំគាល់ស្ទួនក្នុងបញ្ជីឈ្មោះបោះឆ្នោត**




ក្នុងរូបភាពទី៨ ខាងលើបានបង្ហាញថា តួលេខនៃលេខសំគាល់ស្ទួនក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ ២០១៩ មានតួលេខធ្លាក់ចុះបន្តិចបើប្រៀបធៀបជាមួយ តួលេខឆ្នាំ២០១៨។ តួលេខដែលបានធ្លាក់ចុះ ឃើញមាននៅក្នុងឯកសារ អ.ខ ប្រភេទទី១ ប្រភេទទី៣ និង ឯ.អ ប៉ុន្តែឃើញមានការកើនឡើងក្នុងឯកសារ អ.ខ ប្រភេទទី២។

**តារាងទី១៖ ការប្រៀបធៀបតួលេខនៃប្រភេទឯកសារមានលេខសម្គាល់ស្ទួន**

| ល.រ | ប្រភេទ ឯកសារស្ទួន | ចំនួនស្ទួនសរុប | |
|---|---|---|---|
| | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ |
| 1 | អ.ខ ទី១ | 4876 | 4829 |
| 2 | អ.ខ ទី២ | 6681 | 6730 |
| 3 | អ.ខ ទី៣ | 12923 | 12875 |
| 4 | ឯ.អ | 2259 | 1726 |
| សរុប | | 26739 | 26160 |

តារាងទី១ ខាងលើបានបង្ហាញថា ក្នុងចំណោមឯកសារ ដែលមានលេខសំគាល់ស្ទួន ក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ សរុបចំនួន ២៦,១៦០លេខសំគាល់ ដូចករណីអ្នកបោះឆ្នោតដែលមាន អ.ខ ប្រភេទទី២ មានលេខសំគាល់ ០១០៨១៩២០៧ ស្ទួនគ្នាជាមួយអ្នកបោះឆ្នោតមាន អ.ខ ប្រភេទទី៣។

ក្នុងលេខដែលស្ទួននោះ អ.ខ ប្រភេទទី១ មានចំនួន ៤,៨២៩ឈ្មោះ អ.ខ ប្រភេទទី២ មានចំនួន ៦,៧៣០ឈ្មោះ អ.ខ ប្រភេទទី៣ មានចំនួន ១២,៨៧៥ឈ្មោះ និង ឯ.អ មានចំនួន ១,៧២៦ឈ្មោះ ។

**តារាងទី១.១៖ ចំនួនឯកសារដែលមានលេខសម្គាល់ស្ទួនក្នុងប្រភេទដូចគ្នា**

| ល.រ | ប្រភេទ ឯកសារស្ទួន | ចំនួនស្ទួនក្នុងប្រភេទដូចគ្នា | |
|---|---|---|---|
| | | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ |
| 1 | **អ.ខ ទី១** | **249** | **243** |
| 2 | **អ.ខ ទី២** | **350** | **355** |
| 3 | **អ.ខ ទី៣** | **1433** | **1405** |
| 4 | **ឯ.អ** | **961** | **745** |
| **សរុប** | | 2993 | 2748 |

តារាងទី១.១ បានបង្ហាញថា ក្នុងចំណោមឯកសារ ដែលមានលេខសំគាល់ស្ទួនគ្នាលើសពី ២ឡើង និងនៅក្នុងប្រភេទឯកសារតែមួយ ក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ មានចំនួនសរុប ២៧៤៨លេខសំគាល់ ដូចជាករណី ឯកសារ ឯ.អ មានលេខសំគាល់ ៦៨៨៣ ស្ទួនគ្នាចំនួន ៣៩ឈ្មោះ។ ឯកសារ អ.ខ ប្រភេទទី៣ មានលេខសំគាល់ ០៣០០០១៦២២ ស្ទួនគ្នាចំនួន ៣ឈ្មោះ។

ខាងក្រោមនេះ ជាចំនួន តួលេខស្ទួនក្នុងប្រភេទតែមួយ មានដូចខាងក្រោម៖

- អ.ខ ប្រភេទទី១ មានលេខសំគាល់ស្ទួនយ៉ាងតិច ២លេខសំគាល់ មានចំនួន ២៤៣ឈ្មោះ ទាបជាងតួលេខក្នុងឆ្នាំ២០១៨ ។
- អ.ខ ប្រភេទទី២ មានលេខសំគាល់ស្ទួនយ៉ាងតិច២ឈ្មោះ មានចំនួន ៣៥៥ឈ្មោះ កើនជាងតួលេខក្នុងឆ្នាំ២០១៨
- អ.ខ ប្រភេទទី៣ មានលេខសំគាល់ស្ទួនយ៉ាងតិច ២ឈ្មោះ មានចំនួន ១៤០៥ឈ្មោះ ទាបជាងតួលេខក្នុងឆ្នាំ២០១៨
- ឯ.អ មានលេខសំគាល់ស្ទួនយ៉ាងតិច ២ឈ្មោះ មានចំនួន ៧៤៥ឈ្មោះ ទាបជាងតួលេខក្នុងឆ្នាំ២០១៨។

លេខសំគាល់ ឯ.អ ស្ទួនគ្នាក្នុងឆ្នាំ២០១៩នេះ ខុមហ្វ្រែលបានសង្កេតឃើញថា ធ្លាក់ចុះជាងឆ្នាំ២០១៨។ ក្នុងឆ្នាំ២០១៩នេះ ទោះបីឃើញមានការកែសម្រួលលេខសំគាល់ឯកសារ ឯ.អ នេះ តែការកែសម្រួលនេះឃើញថា មិនបានគ្រប់ចំនួនទាំងអស់នៃ ឯ.អ ដែលមានភាពមិនប្រក្រតីនោះទេ។

**ឃ.៤ ភាពមិនប្រក្រតីនៃឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ការចុះឈ្មោះបោះឆ្នោត (ឯ.អ)**

រូបភាពខាងក្រោម គឺជាករណីជាក់ស្តែងនៃភាពមិនប្រក្រតីដែលបានកើតឡើងក្នុងបញ្ជីឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៨ និងបញ្ជីឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០១៩។ ករណីរូបភាពខាងក្រោម គឺការសិក្សាលើភាពមិនប្រក្រតីនៃអ្នកបោះឆ្នោតឈ្មោះ បេង ហ៊ន់ ភេទស្រី មានថ្ងៃខែឆ្នាំកំណើត ០១-០១-១៩៥២ មានលេខ

សំគាល់ ឯ.អ ២១/១៦ នៅក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៨ តែបានកែតម្រូវឡើងវិញនៅឆ្នាំ២០១៩ទៅជាលេខសំគាល់ច្បាស់លាស់គឺលេខសំគាល់ ឯ.អ ០៥២០៩៧១។

**រូបភាពទី៨ ភាពមិនប្រក្រតីនៃលេខសំគាល់អត្តសញ្ញាណសម្រាប់ចុះឈ្មោះបោះឆ្នោត**

**ករណីអ្នកបោះឆ្នោតឈ្មោះ បេង ហ៊ន់ ក្នុងបញ្ជីឈ្មោះឆ្នាំ២០១៨**


បញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៨

កូដខេត្ត: ១៧ ឈ្មោះខេត្ត: សៀមរាប កូដឃុំ: ០១៩ ឈ្មោះឃុំ: ជីក្រែង

ឈ្មោះភូមិ: សណ្ដាន់ លេខកូដការិយាល័យ: ០២៣២ ឈ្មោះការិយាល័យ: សាលារៀនវត្តជីក្រែង

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៣០ | 08-612-407 | | បេង ហ៊ន់<br>ឯ.អ : 21/16 | ស្រី | 01-01-1952 | ភូមិ សណ្ដាន់ |

**ករណីអ្នកបោះឆ្នោតឈ្មោះ បេង ហ៊ន់ ក្នុងបញ្ជីឈ្មោះឆ្នាំ២០១៩**


បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩

កូដខេត្ត: ១៧ ឈ្មោះខេត្ត: សៀមរាប កូដឃុំ: ០១៩ ឈ្មោះឃុំ: ជីក្រែង

ឈ្មោះភូមិ: សណ្ដាន់ លេខកូដការិយាល័យ: ០២៣២ ឈ្មោះការិយាល័យ: សាលារៀនវត្តជីក្រែង

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៣១ | 08-612-407 | | បេង ហ៊ន់<br>ឯ.អ : 0520971 | ស្រី | 01-01-1952 | ភូមិ សណ្ដាន់ |

## ឃ.៥ ប្រភេទអត្តសញ្ញាណសម្រាប់ប្រើប្រាស់ក្នុងបញ្ជីឈ្មោះបោះឆ្នោត

នៅក្នុងរដ្ឋធម្មនុញ្ញមាត្រា ៣៤ថ្មី និងមាត្រា៤៦ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងបទបញ្ជា និងនីតិវិធីសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះប្រការ៦.៤.៦ ភាពមានសិទ្ធិចុះឈ្មោះបោះឆ្នោតបានត្រូវបានកំណត់ដោយលក្ខខណ្ឌធំៗ ចំនួន៥ ក្នុងនោះចំណុចដែលសំខាន់គឺការប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណមានពីរប្រភេទគឺទី១ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(អ.ខ) និងទី២ ឯកសារបញ្ជាក់អត្តសញ្ញាណ (ឯ.អ)។

## ក្រាហ្វិកទី៩ តួលេខនៃឯកសារដែលបានប្រើប្រាស់ក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩




ក្រាហ្វិកទី៩ ខាងលើជាតួលេខរកឃើញផ្អែកលើបញ្ជីឈ្មោះបោះឆ្នោតផ្លូវការឆ្នាំ២០១៩ របស់ គ.ជ.ប។ ក្រាហ្វិកនេះ បានបង្ហាញថា ក្នុងចំណោមអ្នកមានសិទ្ធិបោះឆ្នោតចំនួន ៨,៦២៩,៣៥៧ឈ្មោះ បានប្រើប្រាស់ឯកសារ អ.ខ ឬ ឯ.អ សម្រាប់យកទៅចុះឈ្មោះបោះឆ្នោត ដូចខាងក្រោមគឺ៖

- អ្នកប្រើប្រាស់ឯកសារ អ.ខ សរុបចំនួន ៨,១៩៦,០៣៤ (៩៥ភាគរយ)ឈ្មោះ
- អ្នកប្រើប្រាស់ ឯ.អ សរុបចំនួន ៤៣៣,៣២៣ (៥ភាគរយ)ឈ្មោះ

## ក្រាហ្វិកទី១០ តួលេខអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរបានប្រើប្រាស់ក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩




ក្រាហ្វិកទី១០ ខាងលើ រកឃើញថា ក្នុងចំណោមអ្នកប្រើប្រាស់ អ.ខ សរុបចំនួន ៨,១៩៦,០៣៤ (៩៥ភាគរយ)ឈ្មោះ បានប្រើប្រាស់ប្រភេទ អ.ខ ដូចខាងក្រោម៖

- អ.ខ ប្រភេទទី១ មានចំនួន ៦០៨,៦៤១(៧.៤ភាគរយ)ឈ្មោះ
- អ.ខ ប្រភេទទី២ មានចំនួន ៣៤២,៩៥១(៤.២ភាគរយ)ឈ្មោះ
- អ.ខ ប្រភេទទី៣ មានចំនួន ៧,២៤៤,៤៤២(៨៨.៤ភាគរយ)ឈ្មោះ

**តារាងទី២ តួលេខប្រៀបធៀបការប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណសម្រាប់ចុះឈ្មោះបោះឆ្នោត**

| ល.រ | ឯកសារអត្តសញ្ញាណអ្នកបោះឆ្នោត | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | |
|---|---|---|---|---|---|
| | | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| ១ | អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ (អ.ខ) | **8130493** | **95.15%** | **8196034** | **94.98%** |
| | - អ.ខ ប្រភេទទី១ | **613,769** | **7.5%** | **608,641** | **7.4%** |
| | - អ.ខ ប្រភេទទី២ | **342,910** | **4.2%** | **342,951** | **4.2%** |
| | - អ.ខ ប្រភេទទី៣ | **7,173,814** | **88.2%** | **7,244,442** | **88.4%** |
| ២ | ឯកសារបញ្ជាក់អត្តសញ្ញាណ(ឯ.អ) | **414,392** | **4.8%** | **433,323** | **5.0%** |
| | **សរុប** | 8,544,885 | | 8,629,357 | |

ការប្រើឯកសារ អ.ខ ប្រភេទទី១នេះ ខុមហ្វ្រែលបានសង្កេតឃើញថាមានការធ្លាក់ចុះពីចំនួន ៦១៣,៧៦៩ឈ្មោះ ក្នុងឆ្នាំ២០១៨ មកត្រឹមចំនួន ៦០៨,៦៤១ឈ្មោះ បើប្រៀបធៀបក្នុងឆ្នាំ២០១៩។ ប៉ុន្តែ តួលេខឃើញមានការកើនឡើងនៅក្នុងឆ្នាំ២០១៩ សម្រាប់ការប្រើប្រាស់ អ.ខ ប្រភេទទី២ ទី៣ និង ឯ.អ។

## ឃ.៦ លេខសំគាល់អត្តសញ្ញាណដែលមានលេខសម្គាល់មិនច្បាស់លាស់

លេខអត្តសញ្ញាណដែលមានលេខសម្គាល់មិនច្បាស់លាស់ គឺសំដៅលើលេខសំគាល់ឯកសារដែលប្រើសម្រាប់ចុះឈ្មោះបោះឆ្នោត ក្នុងបញ្ជីឈ្មោះបោះឆ្នោតមានលេខ 0(សូន្យ)។ ការសិក្សាបានរកឃើញថា ករណីលេខសំគាល់របស់ឯកសារបញ្ជាក់អត្តសញ្ញាណ មានលេខ 0 (សូន្យ) មានចំនួន ៤៦ឈ្មោះ ដូចជា ករណីឈ្មោះ **កែវ សុវណ្ណ** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត ០៦/០៧/១៩៧១ ក្នុងខេត្តកំពង់ស្ពឺ។

**រូបភាពទី៩ អ្នកបោះឆ្នោតក្នុងបញ្ជីឈ្មោះបោះឆ្នោត មានលេខសំគាល់ស្មើ0(សូន្យ)**

**ករណីឈ្មោះ កែវ សុវណ្ណ ក្នុងបញ្ជីឆ្នាំ២០១៩**


បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩

កូដខេត្ត: ០៥ ឈ្មោះខេត្ត: កំពង់ស្ពឺ កូដឃុំ: ០៦៤ ឈ្មោះឃុំ: តាំងស្យា

ឈ្មោះភូមិ: ក្អែកពង លេខកូដការិយាល័យ: ១០២៦ ឈ្មោះការិយាល័យ: រោងបុណ្យភូមិក្អែកពង

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៣ | 03-065-977 | | កែវ សុវណ្ណ<br>អ.ខ ទី1 : 000000000 | ប្រុស | 06-07-1971 | ភូមិ ក្អែកពង |

### ករណីឈ្មោះ កែវ សុវណ្ណ ក្នុងបញ្ជីឆ្នាំ២០១៨


បញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៨

កូដខេត្ត: ០៩ ឈ្មោះខេត្ត: កំពង់ស្ពឺ កូដឃុំ: ០៦៤ ឈ្មោះឃុំ: តាំងស្យា
ឈ្មោះភូមិ: ក្អែកពង លេខកូដការិយាល័យ: ១០២៦ ឈ្មោះការិយាល័យ: រោងបុណ្យភូមិក្អែកពង

| | | | | | | |
|---|---|---|---|---|---|---|
| ☐ ៣ | 03-065-977 | | កែវ សុវណ្ណ<br>អ.ខ ទី1 : 000000000 | ប្រុស | 06-07-1971 | ភូមិ ក្អែកពង |

### ករណីឈ្មោះ ខេ រិទ្ធី ក្នុងបញ្ជីឆ្នាំ២០១៩


បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩

កូដរាជធានី: ១២ ឈ្មោះរាជធានី: ភ្នំពេញ កូដសង្កាត់: ០៦៨ ឈ្មោះសង្កាត់: គីឡូម៉ែត្រលេខ ៦
ឈ្មោះភូមិ: ក្រោលគោ លេខកូដការិយាល័យ: ១១៤៩ ឈ្មោះការិយាល័យ: វត្តទួលសន្តិវ័ន្ត

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ២២ | 06-321-429 | | ខេ រិទ្ធី<br>អ.ខ ទី2 : 000000000 | ប្រុស | 15-10-1981 | ផ្ទះ ១៨៧ ផ្លូវ លំ |

### ករណីឈ្មោះ ខេ រិទ្ធី ក្នុងបញ្ជីឆ្នាំ២០១៨


បញ្ជីបោះឆ្នោតដំបូងឆ្នាំ២០១៨

កូដរាជធានី: ១២ ឈ្មោះរាជធានី: ភ្នំពេញ កូដសង្កាត់: ០៦៨ ឈ្មោះសង្កាត់: គីឡូម៉ែត្រលេខ ៦
ឈ្មោះភូមិ: ក្រោលគោ លេខកូដការិយាល័យ: ១១៤៩ ឈ្មោះការិយាល័យ: វត្តទួលសន្តិវ័ន្ត

| | | | | | | |
|---|---|---|---|---|---|---|
| ☐ ២២ | 06-321-429 | | ខេ រិទ្ធី<br>អ.ខ ទី2 : 000000000 | ប្រុស | 15-10-1981 | ផ្ទះ ១៨៧ ផ្លូវ លំ |

### ឃ.៧ ករណីសិក្សាពីអ្នកបោះឆ្នោតដែលបានរកឃើញថាមានទិន្នន័យដូចគ្នាក្នុងបញ្ជី

ផ្អែកលើឈ្មោះដូចគ្នា/ស្ទួន ក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ដែល ខុមហ្វ្រែល បានចុះសិក្សាជាក់ស្តែង និងផ្ទៀងផ្ទាត់ជាមួយអ្នកបោះឆ្នោត ចំនួន ៤ករណី/នាក់/ខេត្ត ក្នុងគោលបំណងដើម្បីស្វែងរកហេតុផលដែលនាំឱ្យមានឈ្មោះដូចគ្នា/ស្ទួន មាននៅក្នុងខេត្តបាត់ដំបង ខេត្តព្រៃវែង រតនគិរី និងខេត្តកណ្តាល។

## រូបភាពទី១០ ករណីឈ្មោះដូចគ្នាក្នុងខេត្តបាត់ដំបង



**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: **០២** ឈ្មោះខេត្ត: **បាត់ដំបង** កូដឃុំ: **០៩៦** ឈ្មោះឃុំ: **តាក្រី**
ឈ្មោះភូមិ: **ផ្លូវប្រាំមួយ** លេខកូដការិយាល័យ: **១៩៣៤** ឈ្មោះការិយាល័យ: **បឋមសិក្សាសាមសិប**

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៨ | 01-387-800 | | កែវ គន្ធា<br>អ.ខ ទី3 : 061040111 | ស្រី | 01-07-1989 | ផ្ទះ 331 ក្រុម 22 |

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: **២៥** ឈ្មោះខេត្ត: **ត្បូងឃ្មុំ** កូដឃុំ: **០២០** ឈ្មោះឃុំ: **ចាន់មូល**
ឈ្មោះភូមិ: **ចាន់មូល** លេខកូដការិយាល័យ: **០២៨៣** ឈ្មោះការិយាល័យ: **សាលារៀនភូមិចាន់មូល**

| | | | | | | |
|---|---|---|---|---|---|---|
| ☐ ៩ | 11-089-322 | | កែវ គុន្ធា<br>អ.ខ ទី2 : 061040111 | ស្រី | 01-07-1989 | ភូមិ ចាន់មូល |

តាមរយៈការចុះជួបរបស់លេខាខុមហ្វ្រែលជាមួយមេឃុំ និងស្មៀនឃុំ ស្ថិតនៅក្នុងឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបងគឺ លោកមេឃុំ រស់ គប ប្រធានក្រុមប្រឹក្សា ឃុំតាក្រី និងក៏ដូចជាស្មៀនឃុំ បានបញ្ជាក់ដូចគ្នាថា អ្នកបោះឆ្នោតឈ្មោះ កែវ គន្ធា ដែលមានលេខរៀងទី៨ ពិតជារស់នៅក្នុងភូមិផ្លូវប្រាំមួយ ឃុំតាក្រី ស្រុកកំរៀង ខេត្តបាត់ដំបង ប្រាកដមែន។

លោកមេឃុំ បានបន្ថែមទៀតថា៖ អ្នកបោះឆ្នោតឈ្មោះ កែវ គន្ធា បានរស់នៅក្នុងភូមិឃុំខាងលើពិតប្រាកដមែន។ មុនឆ្នាំ២០១៩ ទោះបីអ្នកបោះឆ្នោតរូបនេះ ទៅធ្វើការនៅទីណាក៏ដោយ ក៏គាត់ត្រឡប់មកវិញដែរ តែក្នុងឆ្នាំ២០១៩នេះ គាត់មិនឃើញត្រឡប់មកវិញនោះទេ ហើយព័ត៌មានពីការដូរទីលំនៅក៏មិនទាន់បានទទួលដែរ។

## រូបភាពទី១១ ករណីឈ្មោះដូចគ្នាក្នុងខេត្តព្រៃវែង



**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ០៨ ឈ្មោះខេត្ត: កណ្ដាល កូដឃុំ: ០៨៣ ឈ្មោះឃុំ: សំបួរ
ឈ្មោះភូមិ: ព្រែកចារ លេខកូដការិយាល័យ: ០៨៨៦ ឈ្មោះការិយាល័យ: បឋមសិក្សាព្រែកចារ (ត្បូង)

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐៤៨ | 04-804-043 | | ច្រឹក ជា<br>អ.ខ ទី3 : 050147835 | ស្រី | 12-12-1980 | ភូមិ ព្រែកចារ |

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ១៤ ឈ្មោះខេត្ត: ព្រៃវែង កូដឃុំ: ០៧៨ ឈ្មោះឃុំ: បឹងដោល
ឈ្មោះភូមិ: អំពិល លេខកូដការិយាល័យ: ១២១០ ឈ្មោះការិយាល័យ: វត្តអំពិល

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐៦៦ | 07-754-062 | | ច្រឹក ជា<br>អ.ខ ទី1 : 050147835 | ស្រី | 12-12-1980 | ភូមិ អំពិល |

នៅក្នុងខែកញ្ញា ឆ្នាំ២០១៩ លេខាខុមហ្វ្រែលខេត្តព្រៃវែង បានចុះសិក្សានៅក្នុងភូមិអំពិល ឃុំបឹងដោល ស្រុកព្រះស្ដេច ខេត្តព្រៃវែង។ ខណៈពេលចុះដល់ភូមិ ដូចអាសយដ្ឋានដែលមានក្នុងបញ្ជីឈ្មោះ លេខាខុមហ្វ្រែលបានជួបជាមួយមេភូមិជាដំបូង និងបានសាកសួរពីវត្តមានអ្នកបោះឆ្នោតដូចមានរូបក្នុងបញ្ជីដែលត្រូវស្វែងរក។ ក្រោយពីការពិនិត្យ លោកមេភូមិ បានបញ្ជាក់ថា ក្នុងចំណោមអ្នកបោះឆ្នោតទាំងពីរនាក់ដែលមានរូបថតដែលបានបង្ហាញ គឺអ្នកបោះឆ្នោត ឈ្មោះ ច្រឹក ជា លេខរៀងទី៦៦ ស្ថិតនៅភូមិអំពិល ឃុំបឹងដោល ស្រុកព្រះស្ដេច ខេត្តព្រៃវែង ពិតជាមានទិន្នន័យត្រឹមត្រូវ រូបភាពដូច និងមានអាសយដ្ឋានពិតប្រាកដនៅក្នុងភូមិដូចបានរៀបរាប់ខាងលើនេះមែន រីឯអ្នកបោះឆ្នោតដែលមានឈ្មោះ ច្រឹក ជា លេខរៀងទី៤៨ ដែលរស់នៅព្រែកចារ ឃុំសំបួរ ស្រុកល្វាឯម ខេត្តកណ្ដាល គឺមិនដែលស្គាល់នោះទេ។ បន្ថែមលើព័ត៌មានរបស់លោកមេភូមិ បងស្រី និងម្ដាយរបស់អ្នកបោះឆ្នោតឈ្មោះ ច្រឹក ជា ដែលរស់នៅក្នុងខេត្តព្រៃវែង បានបញ្ជាក់ផងដែរថា គាត់មិនដែលស្គាល់ទេអ្នកបោះឆ្នោតមានលេខរៀងទី៤៨ តែអ្នកបោះឆ្នោតដែលមានលេខរៀងទី៦៦ ពិតប្រាកដណាស់ជាកូន និងប្អូនរបស់ពួកគាត់ ហើយឈ្មោះ ច្រឹក ជា បានទៅធ្វើការនៅភ្នំពេញជាមួយប្ដីបាត់ហើយ។

ខុមហ្វ្រែល មិនអាចសិក្សាអ្នកបោះឆ្នោតនៅក្នុងខេត្តកណ្ដាលបានទេ ហើយក៏មិនសន្និដ្ឋានថា អ្នកទាំងពីរនេះ ពិតជាអ្នកបោះឆ្នោតពីរនាក់ផ្សេងគ្នា ឬតែមួយនោះដែរ តែទិន្នន័យដូចគ្នាទាំងលេខឯកសារ។

## រូបភាពទី១២ ករណីឈ្មោះដូចគ្នាក្នុងខេត្តកណ្ដាល



**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ០៨ ឈ្មោះខេត្ត: កណ្ដាល កូដសង្កាត់: ១៣៨ ឈ្មោះសង្កាត់: ស្វាយរលំ

ឈ្មោះភូមិ: ភូមិលេខ ៥ លេខកូដការិយាល័យ: ១៩៨៨ ឈ្មោះការិយាល័យ: សាលារៀនដើមអង្កោល

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ២២១ | 05-137-788 | | ផុន ផល<br>អ.ខ ទី3 : 020869633 | ប្រុស | 08-04-1994 | ភូមិ ភូមិលេខ ៥ |
| ☐ ២២២ | 05-137-793 | | ផុន ផល ផុន ភា (ឈ្មោះពិត)<br>អ.ខ ទី2 : 020869633 | ប្រុស | 08-04-1994 | ភូមិ ភូមិលេខ ៥ |

តាមរយៈការសិក្សារបស់មន្ត្រីខុមហ្វ្រែលខេត្តកណ្ដាលបានចុះសិក្សាករណីអ្នកបោះឆ្នោតឈ្មោះ ផុន ផល មានអត្តសញ្ញាណប័ណ្ណប្រភេទ២ និងប្រភេទ៣ មានលេខសំគាល់ ០២០៨៦៩៦៣៣ដូចគ្នា ស្ថិតនៅភូមិលេខ៥ ឃុំស្វាយរលំ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

តាមការបញ្ជាក់ពីលោក លី នួចស៊ីម ជំទប់ឃុំទី១ បានឱ្យដឹងថា អ្នកបោះឆ្នោតដែលមានលេខរៀង ២២១ និង២២២ ខាងលើជាមនុស្ស ពីរនាក់ផ្សេងគ្នា និងជាបងប្អូននឹងគ្នា។ អ្នកបោះឆ្នោតមានលេខរៀង ២២១ មានឈ្មោះ ផុន ផល រីឯអ្នកបោះឆ្នោតមានលេខរៀង ២២២ មានឈ្មោះថា ផុន ភា ត្រូវជាប្អូន។ លោកបន្តទៀតថា អ្នកទាំងពីរបានច្រឡំអត្តសញ្ញាណប័ណ្ណគ្នាពេលចុះឈ្មោះ តែស្មៀនបានផ្ដល់ជារបាយការណ៍ជូនទៅស្ថាប័នរៀបចំការបោះឆ្នោតរួចរាល់អស់ហើយ។

តាមការបញ្ជាក់អះអាងពីអ្នកបោះឆ្នោតលេខរៀងទី២២២ ឈ្មោះ ផុន ភា (ថ្ងៃខែឆ្នាំកំណើតៈ ១២ ឧសភា ១៩៩៩) តាមការសាកសួរតាមទូរស័ព្ទ (០៨១ ៩៩៧ ៩០០) បានឲ្យដឹងថា៖ កាលពីឆ្នាំ២០១៦ បងឈ្មោះ ផុន ផល នឹងរូបខ្លួនឈ្មោះ ផុន ភា បានទៅចុះឈ្មោះបោះឆ្នោតជាមួយគ្នា នៅទីស្នាក់ការឃុំ ស្វាយរលំ ដោយមានម្ដាយរបស់គាត់ជាអ្នកនាំទៅ និងជាអ្នកទុកដាក់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ពួកគាត់ទាំងពីរនាក់។ នៅពេលទៅចុះឈ្មោះ ម្ដាយក៏បានហុចអត្តសញ្ញាណប័ណ្ណ ដើម្បីឲ្យឈ្មោះ ផុន ផល ជាបងប្រុសចូលទៅចុះឈ្មោះមុន បន្ទាប់ពីចុះឈ្មោះរួចរាល់ហើយ ឈ្មោះ ផុន ផល ក៏បានយកអត្តសញ្ញាណប័ណ្ណរបស់ខ្លួនយកមកប្រគល់ឲ្យម្ដាយរបស់គាត់រក្សាទុកវិញ បន្ទាប់មករូបខ្លួន(ឈ្មោះ ផុន ភា) ក៏បានចូលទៅចុះឈ្មោះវិញម្ដង ស្រាប់តែម្ដាយរបស់គាត់បានហុចអត្តសញ្ញាណប័ណ្ណរបស់ឈ្មោះ ផុន ផល ជាប្រភេទ២ ប្រគល់ឲ្យទៅរូបខ្លួន យកទៅចុះឈ្មោះ ដោយមិនបានមើលឲ្យបានល្អិតល្អន់នោះទេ ទើបបណ្ដាលឲ្យមានកំហុសកើតមានដូច្នេះ។

**រូបភាពទី១៣ ករណីឈ្មោះ និងរូបថតដូចគ្នាក្នុងខេត្តរតនគិរី**



**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ១៦ ឈ្មោះខេត្ត: **រតនគិរី** កូដឃុំ: ០៤១ ឈ្មោះឃុំ: ប៉ុង

ឈ្មោះភូមិ: **បានប៉ុង** លេខកូដការិយាល័យ: **០២៤០** ឈ្មោះការិយាល័យ: **បឋមសិក្សាបានប៉ុង**

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៣៩២ | 12-320-467 | | វ៉ាន់ សាវ៉ាក់<br>អ.ខ ទី3 : 240133297 | ប្រុស | 06-07-1988 | ភូមិ បានប៉ុង |

**បញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០១៩**

កូដខេត្ត: ១៦ ឈ្មោះខេត្ត: **រតនគិរី** កូដឃុំ: ០១៨ ឈ្មោះឃុំ: ត្រពាំងក្រហម

ឈ្មោះភូមិ: **ភូមិ ២** លេខកូដការិយាល័យ: **០១២២** ឈ្មោះការិយាល័យ: **វិទ្យាល័យត្រពាំងក្រហម**

| ល.រ | អត្តលេខ | រូបថត | នាមត្រកូល និងនាមខ្លួន | ភេទ | ថ្ងៃខែឆ្នាំកំណើត | អាសយដ្ឋានបច្ចុប្បន្ន |
|---|---|---|---|---|---|---|
| ☐ ៣២៧ | 08-502-593 | | វ៉ាន់ សាវ៉ាក់<br>អ.ខ ទី3 : 240133297 | ប្រុស | 06-07-1988 | ផ្លូវ ៧៨ |

នៅថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៩ មន្ត្រីខុមហ្វ្រែលបានចុះទៅភូមិបានប៉ុង ឃុំប៉ុង ស្រុកវ៉ឺនសៃ ខេត្តរតនគិរី ដើម្បីសិក្សាករណីអ្នកបោះឆ្នោតឈ្មោះ វ៉ាន់ សាវ៉ាក់ ដែលមានទិន្នន័យ និងរូបថតដូចគ្នា។ តាមរយៈការបង្ហាញរបស់មេភូមិឈ្មោះ ថុន នួន បញ្ជាក់ថា រូបថត និងទិន្នន័យនៃអ្នកបោះឆ្នោតពិតជាបានរស់នៅក្នុងភូមិឃុំខាងលើនេះពិតប្រាកដមែន។ កាលពីមុនអ្នកបោះឆ្នោតឈ្មោះ វ៉ាន់ សាវ៉ាក់ គាត់បានរស់នៅក្នុងភូមិ២ ឃុំត្រពាំងក្រហម ដែលជាស្រុកកំណើតរបស់គាត់ តែក្រោយមកអ្នកបោះឆ្នោតរូបនេះ បានរៀបការជាមួយប្រពន្ធរបស់គាត់ដូចមានទីតាំងនៅក្នុងភូមិបានប៉ុង ខាងលើ។ ក្នុងករណីឈ្មោះស្ទួននេះ គាត់ក៏មិនដឹងច្បាស់ពីមូលហេតុដែលនាំឱ្យមានឈ្មោះស្ទួននោះដែរ។

ករណីនេះ មន្ត្រីរបស់ខុមហ្វ្រែលបានជួបជាមួយអ្នកបោះឆ្នោតផ្ទាល់គឺលោក វ៉ាន់ សាវ៉ាក់ ដើម្បីបញ្ជាក់ពីឈ្មោះស្ទួនក្នុងបញ្ជីនេះ។ សមីខ្លួនបានបញ្ជាក់ពីដំណើររឿងដូចអ្វីដែលលោកមេភូមិបានបញ្ជាក់ខាងលើពិតប្រាកដមែន។ អ្នកបោះឆ្នោតបានប្រាប់បន្ថែមទៀតថា ពេលចុះឈ្មោះចុងក្រោយ គាត់បានប្រាប់ទៅស្មៀន និងការីកុំព្យូទ័រ អំពីឈ្មោះរបស់គាត់ធ្លាប់មាននៅក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃទីតាំងផ្សេងដែរ តែមិនដឹងហេតុអ្វីបានជាឈ្មោះគាត់នៅតែមានក្នុងទីកន្លែងចាស់ទៀត។ អ្នកបោះឆ្នោត បានបញ្ជាក់បន្ថែមថា ឈ្មោះដែលមាននៅក្នុងការិយាល័យលេខ ០២៤០ គាត់ទើបតែចុះឈ្មោះក្នុងខែឧសភា ឆ្នាំ២០១៩ ហើយគាត់មិនដឹងច្បាស់ពីមូលហេតុដែលនាំឱ្យមានឈ្មោះស្ទួននោះដែរ។

តាមរយៈលោកស្មៀនឃុំ លោក ជុន ប៊ុនចាន់ បញ្ជាក់ថា គាត់បានភ្លេចគូសសញ្ញាត្រង់កន្លែង «ការប្តូរការិយាល័យក្នុងឃុំសង្កាត់ (សូមមើលរូបភាពទី១៤)»។ លោកស្មៀនឃុំបានបន្ថែមទៀតថា បើទោះបីគាត់មិនបានគូសសញ្ញា តែហេតុអ្វីមន្ត្រីកុំព្យូទ័រមិនដឹងថារូបនេះមានរួចហើយ នៅពេលថតស្នាមក្រយៅដៃនោះ។

## រូបភាពទី១៤ បង្កាន់ដៃបញ្ជាក់ការចុះឈ្មោះបោះឆ្នោត




តាមរយៈការីកុំព្យូទ័រ ក្រោយបានជជែក និងបង្ហាញពីករណីអ្នកបោះឆ្នោតមានឈ្មោះស្ទួនខាងលើ លោកបានបញ្ជាក់ថា លោកក៏មិនដឹងដែរ ហើយក៏មិនដឹងថាគាត់មានឈ្មោះពីរដូចគ្នាដែរ។ ម្យ៉ាងទៀត លោកថា បើសិនជាមានឈ្មោះរួចហើយ គួរណាឈ្មោះចាស់បង្ហាញមក តែគាត់មិនបានឃើញឈ្មោះចាស់បង្ហាញមកទេ ខណៈពេលដែលគាត់ផ្តិតស្នាមក្រយៅដៃដំបូង។

## ខ. ការសម្ភាសន៍ប្រជាពលរដ្ឋ

គម្រោងធ្វើសវនកម្មបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ គឺមានគោលបំណងក្នុងការសិក្សាពីគុណភាពបញ្ជីឈ្មោះបោះឆ្នោត និងបញ្ហាប្រឈមទាក់ទងការចុះឈ្មោះបោះឆ្នោត។ វិធីសាស្ត្រដែលត្រូវប្រើនេះគឺ វិធីសាស្ត្រពីបញ្ជីទៅមនុស្ស(L2P)។ វិធីសាស្ត្រនេះ គឺអនុញ្ញាតឱ្យអ្នកស្ម័គ្រចិត្តធ្វើការចុះទៅស្វែងរកវត្តមានអ្នកមានឈ្មោះបោះឆ្នោតដែលមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ តាមរយៈសំណាកអ្នកមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតចាប់ដោយចៃដន្យចេញពី ២៥រាជធានី ខេត្ត។ ការស្វែងរកវត្តមាននេះ គឺដើម្បីផ្ទៀងផ្ទាត់ថាតើពួកគេមានវត្តមានពិតប្រាកដនៅក្នុងភូមិ ដូចព័ត៌មានដែលបានបង្ហាញនៅលើបញ្ជីឈ្មោះនោះពិតមែនដែរឬទេ?។ បន្ទាប់មកធ្វើការសម្ភាសន៍អ្នកបោះឆ្នោតរូបនោះ និងធ្វើការផ្ទៀងផ្ទាត់ព័ត៌មានជាមួយឯកសាររបស់គាត់។

ការសិក្សានេះ មិនបានប្រែក្លាយជាសំណាកពេញលេញនោះទេ វាគ្រាន់តែជាការសិក្សាក្នុងទីតាំងចំនួន ៦ខេត្ត ក្នុងចំណោម ២៥រាជធានីខេត្ត មានដូចជា ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តកំពត ខេត្តកណ្តាល ខេត្តព្រៃវែង និងខេត្តរតនៈគិរី ដែលមានអ្នកផ្តល់បទសម្ភាសន៍ ឬអ្នកបោះឆ្នោតដែលត្រូវធ្វើការស្វែងរក/សម្ភាសន៍ ចំនួន ៧៤០នាក់ ក្នុងភូមិចំនួន ៧៤ភូមិ/ការិយាល័យ។

ការចុះស្វែងរកវត្តមានអ្នកមានឈ្មោះបោះឆ្នោត និងធ្វើការសម្ភាសន៍ បានប្រើប្រាស់អ្នកស្ម័គ្រចិត្តចំនួន ៦៧នាក់ (ស្រីចំនួន ២៣នាក់)។ ការសម្ភាសន៍នេះ បានប្រើរយៈពេលចំនួន ២ថ្ងៃ ហើយសម្ភាសន៍អ្នកបោះឆ្នោតចំនួន ១០នាក់ក្នុងមួយភូមិ។

ទិន្នន័យដែលធ្វើការវិភាគ ចេញពីអ្នកបានផ្តល់ចម្លើយចំនួន ៧២៤នាក់ នៃផែនការត្រូវសម្ភាសន៍ចំនួន ៧៤០នាក់។ ដូចលទ្ធផលនៃការវិភាគខាងក្រោម មិនបង្ហាញជាសំណាកនោះទេ វាគ្រាន់តែជាករណីសិក្សា ឬនិន្នាការនៃលទ្ធផល(Trend)ប៉ុណ្ណោះ។

## ង.១ ការផ្ទៀងផ្ទាត់វត្តមានអ្នកបោះឆ្នោត

### ក្រាហ្វិកទី១១ ការផ្ទៀងផ្ទាត់វត្តមានអ្នកបោះឆ្នោត ជាមួយបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩




ក្រាហ្វិកទី១១ ជាលទ្ធផលបានពីការផ្ទៀងផ្ទាត់ឈ្មោះអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១៩ ជាមួយវត្តមានអ្នកបោះឆ្នោតនៅក្នុងទីតាំងដែលបានបង្ហាញក្នុងបញ្ជី។ លទ្ធផលនៃការស្វែងរកនេះបានបង្ហាញថា អ្នកបោះឆ្នោត ៩៩.៧ភាគរយនៃអ្នកបោះឆ្នោតបានឆ្លើយតបចំនួន ៧២៤នាក់ បានស្គាល់ និងបានបញ្ជាក់ពីវត្តមានរបស់ពួកគាត់បានរស់នៅក្នុងទីតាំងដូចក្នុងបញ្ជីពិតប្រាដមែន។ អ្នកបោះឆ្នោត ០.៣ភាគរយមិនត្រូវបានអាជ្ញាធរមូលដ្ឋាន ភូមិ និងឃុំបញ្ជាក់ថា គាត់ជានរណា មកពីណានោះទេ។ អ្នកបោះឆ្នោតដែលមិនអាចបញ្ជាក់បាននោះមានឈ្មោះថា **សុខ ខេង** មានអ.ខ ០២១១៩៩៧៣៦ ស្ថិតនៅក្នុងការិយាល័យលេខ ២០៥ លេខរៀងក្នុងបញ្ជី ៣២៧ ភូមិស្ពោកន្លែង២ ឃុំដីឥដ្ឋ ខេត្តកណ្តាល។ និងអ្នកបោះឆ្នោតឈ្មោះ **តែម ប៊ូឡា** មាន អ.ខ ១៩០៥២៣៨៦៥ ស្ថិតនៅក្នុងការិយាល័យលេខ ២០៩ លេខរៀងក្នុងបញ្ជី ៨៩ ភូមិគោកច្រាប ឃុំស្រះរាំង ខេត្តបន្ទាយមានជ័យ។

## ក្រាហ្វិកទី១២ វត្តមានអ្នកបោះឆ្នោតក្នុងពេលជួបសម្ភាសន៍ និងផ្ទៀងផ្ទាត់




ក្រាហ្វិក១២ ខាងលើនេះ បង្ហាញថា ក្នុងចំណោមអ្នកដែលបានស្គាល់ និងទទួលការបញ្ជាក់ពីមេភូមិ ឬអនុភូមិ ឬចាស់ព្រឹទ្ធាចារ្យ អ្នកសង្កេតការណ៍ខុមហ្វ្រែល បានជួបគាត់ផ្ទាល់ចំនួន ៥២.៩ភាគរយ និង ៤៧.១ ភាគរយទៀតមិនបានជួបនោះទេ។ តារាងខាងក្រោម ជាមូលហេតុដែលអ្នកសង្កេតការណ៍មិនបានជួបជាមួយអ្នកបោះឆ្នោតទាំងនោះ ព្រោះថាអ្នកបោះឆ្នោត ៧៧.៣ភាគរយនៃអ្នកបោះឆ្នោតមិនបានជួប គឺអ្នកខ្លះបានធ្វើការងារនៅឆ្ងាយ យូរៗទើបមកផ្ទះម្តង អ្នកខ្លះទៀតធ្វើការនៅក្រៅប្រទេស (ព័ត៌មានលម្អិត ដូចបង្ហាញក្នុងតារាងទី៣ ខាងក្រោម) ក្រៅពីចំនួននេះ ពួកគេបានចេញទៅខាងក្រៅផ្ទះមិនអាចជួបខណៈពេលអ្នកស្ម័គ្រចិត្តចុះសម្ភាសន៍ ឬអ្នកបោះឆ្នោតរស់នៅទីតាំងផ្សេង។

## តារាងទី៣ មូលហេតុមិនបានជួបអ្នកបោះឆ្នោតដោយផ្ទាល់

| ល.រ | បរិយាយហេតុផល | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | ទៅធ្វើការឆ្ងាយពីផ្ទះ យូរៗមកម្តង | **165** | **48.7%** |
| ២ | ទៅធ្វើការវិលល្ងាច | **63** | **18.6%** |
| ៣ | ធ្វើការនៅក្រៅប្រទេស | **34** | **10.0%** |
| ៤ | ឈឺ/មានធុរៈចាំបាច់ចេញក្រៅផ្ទះ | **26** | **7.7%** |
| ៥ | បានផ្លាស់ប្តូរទីលំនៅ | **17** | **5.0%** |
| ៦ | គាត់តែងតែងរស់នៅទីតាំងផ្សេង | **6** | **1.8%** |
| ៧ | គាត់បានមរណៈភាពហើយ | **4** | **1.2%** |
| ៨ | ផ្សេងៗ | **24** | **7.1%** |
| **សរុប** | | 339 | 100.0% |

**ក្រាហ្វិកទី១៣ អ្នកពាក់ព័ន្ធដែលបានផ្តល់ការការបញ្ជាក់ចំពោះវត្តមានអ្នកបោះឆ្នោត**




ក្រាហ្វិកទី១៣ ខាងលើបង្ហាញពីអ្នកពាក់ព័ន្ធក្នុងភូមិគោលដៅដូចមានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតបានបញ្ជាក់ និងអះអាងពីវត្តមានឈ្មោះអ្នកមានក្នុងបញ្ជីឈ្មោះបោះឆ្នោត២០១៩ ខណៈដែលអ្នកសង្កេតការណ៍បានចុះដល់មូលដ្ឋាន។ លទ្ធផលបង្ហាញថា អ្នកបញ្ជាក់ពីវត្តមានរបស់អ្នកបោះឆ្នោតថាបានស្គាល់ ឬមិនបានស្គាល់នោះគឺ ៨២.៦ភាគរយ ជាមេភូមិ ១៤.៤ភាគរយ ជាអនុភូមិ និង៣ភាគរយ ជាចាស់ព្រឹទ្ធាចារ្យដែលរស់នៅក្នុងភូមិ។

**ង.២ ព័ត៌មានពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាប់អ្នកបោះឆ្នោតប្រើប្រាស់**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គ.ជ.ប បានឱ្យដឹងថា អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរប្រភេទទី២ ដែលនៅមានសុពលភាព ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ប្រភេទទី៣ ឬឯកសារបញ្ជាក់អត្តសញ្ញាណបម្រើឱ្យការចុះឈ្មោះបោះឆ្នោត គឺជាឯកសារតែមួយគត់ ដែលប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវប្រើប្រាស់សម្រាប់ការចុះឈ្មោះបោះឆ្នោតឆ្នាំ២០១៩។

យោងតាមសេចក្តីអំពាវនាវរបស់ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ កាលពីថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ បានអំពាវនាវសូមឱ្យប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលកំពុងប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូចាស់ទាំងអស់ និងប្រជាពលរដ្ឋដែលគ្រប់អាយុ ១៥ឆ្នាំឡើង ដែលពុំទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី រួសរាន់ទៅបំពេញបែបបទស្នើសុំផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូថ្មី ព្រោះអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូចាស់ទាំងអស់ នឹងត្រូវអស់សុពលភាពប្រើប្រាស់នៅត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ខាងមុខនេះ។

សេចក្តីអំពាវនាវរបស់ក្រសួងមហាផ្ទៃ និងការកំណត់សម្គាល់របស់ស្ថាប័ន គ.ជ.ប នេះ បានបង្ហាញថា រាល់ឯកសារអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គំរូប្រភេទទី១ និងគំរូប្រភេទទី២ អស់សុពលភាពមិនអាចប្រើប្រាស់សម្រាប់ការចុះឈ្មោះបោះឆ្នោតបាននោះទេ។

## ក្រាហ្វិកទី១៤ ព័ត៌មានពីសុពលភាពនៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(អ.ខ) សម្រាប់ការចុះឈ្មោះបោះឆ្នោត




តាមរយៈសេចក្តីអំពាវដូចបានលើកឡើងខាងលើ ខុមហ្វ្រែលបានសាកសួរប្រជាពលរដ្ឋនៅមូលដ្ឋានអំពីព័ត៌មានទាក់ទង អ.ខ ប្រភេទទី១ និងប្រភេទទី២ អស់សុពលភាពសម្រាប់ការចុះឈ្មោះបោះឆ្នោត។ ជាលទ្ធផលដូចបានបង្ហាញនៅក្នុងក្រាហ្វិកទី១៤ ខាងលើថា ២០.៤ភាគរយ យល់ថាមិនអាចប្រើប្រាស់បាន រីឯ ២៣.៣ភាគរយ យល់ថាអាចប្រើប្រាស់បាន ហើយ ៩.៣ភាគរយ យល់មិនច្បាស់លាស់អំពីព័ត៌មាននេះ និង ៤៧.០ភាគរយឆ្លើយថាមិនដឹងអំពីព័ត៌មានទាក់ទងលើឯកសារនេះ។

## ង.៣ ទស្សនៈអ្នកបោះឆ្នោតជុំវិញប្រជាពលរដ្ឋចំណាកស្រុក

**ក្រាហ្វិកទី១៥ ព័ត៌មានទាក់ទងសាច់ញាតិអ្នកបោះឆ្នោតមិនបានចុះឈ្មោះ**




តាមរយៈការផ្តល់បទសម្ភាសន៍ពីអ្នកបោះឆ្នោតជាលទ្ធផលដូចបានបង្ហាញនៅក្នុងក្រាហ្វិក១៥ ថា ៥.៥ភាគរយនៃអ្នកផ្តល់ចម្លើយគឺមានសាច់ញាតិរបស់ពួកគេយ៉ាងហោចណាស់មួយនាក់មិនបានចុះឈ្មោះបោះឆ្នោតនូវឡើយ។ ភាគច្រើននៃសាច់ញាតិរបស់ពួកគេដែលមិនបានចុះឈ្មោះបោះឆ្នោត គឺមកពីអ្នកទាំងនោះ ចំនួនខ្លះទៅធ្វើការនៅក្រៅប្រទេស ខ្លះធ្វើការនៅក្រៅស្រុកដែលនៅឆ្ងាយមិនអាចវិលត្រឡប់មកចុះឈ្មោះបានដោយស្រួល។

**ក្រាហ្វិកទី១៦ ទស្សនៈការយល់ឃើញចំពោះប្រជាពលរដ្ឋចំណាកស្រុក និងការចុះឈ្មោះ**



ទាក់ទងប្រជាពលរដ្ឋដែលបានចំណាកស្រុកនៅក្រៅប្រទេស ជាមួយការចុះឈ្មោះបោះឆ្នោត អ្នកបោះឆ្នោតដែលបានផ្តល់បទសម្ភាសន៍បានបង្ហាញជាលទ្ធផលដូចក្នុងក្រាហ្វិកទី១៦ ខាងលើថា ៥១.៤ភាគរយ លើកទឹកចិត្តសុំឱ្យមានការចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋដែលបានចំណាកស្រុកនៅក្រៅប្រទេស ។អ្នកបោះឆ្នោតផ្តល់សម្ភាសន៍ ៣.៣ភាគរយ យល់ឃើញថាមិនចាំបាច់មានការលើកទឹកចិត្តទេ។ រីឯអ្នកបោះឆ្នោតបានផ្តល់បទសម្ភាសន៍ ៤៥.៣ភាគរយ គ្មានយោបល់ក្នុងការលើកទឹកចិត្តឱ្យមាន ឬគ្មាន សម្រាប់ការចុះឈ្មោះនៅក្រៅប្រទេសនោះទេ។

## ង.៤ ប្រភពព័ត៌មានទាក់ទងការចុះឈ្មោះបោះឆ្នោត

**តារាងទី៤ ប្រភពព័ត៌មានទាក់ទងការចុះឈ្មោះបោះឆ្នោត**

| ល.រ | ប្រភពព័ត៌មាន | ចំនួន | ភាគរយ |
|---|---|---|---|
| ១ | តាមរយៈប្រធានភូមិឬ អនុភូមិ | 257 | 26.8% |
| ២ | ទូរទស្សន៍ | 164 | 17.1% |
| ៣ | តាមរយៈអាជ្ញាធរឃុំ/សង្កាត់ | 120 | 12.5% |
| ៤ | តាមរយៈឧគ្ឃោសនសព្ទ (ការប្រកាសមេក្រូ) | 112 | 11.7% |
| ៥ | វិទ្យុ | 114 | 11.9% |
| ៦ | ខិតប័ណ្ណ/ប៉ុស្ទ័រ និងតាមរយៈផ្ទាំងបដាដែលចង ឬបិទតាមផ្លូវអគារ | 66 | 6.9% |
| ៧ | លិខិតអញ្ជើញចុះឈ្មោះរបស់ គ.ជ.ប | 33 | 3.4% |
| ៨ | មន្ត្រីបោះឆ្នោតមូលដ្ឋាន | 27 | 2.8% |
| ៩ | តាមរយៈគ្រួសារ/មិត្តភក្តិ និងសហគមន៍ | 27 | 2.8% |
| ១០ | តាមរយៈហ្វេសប៊ុក | 17 | 1.8% |
| ១១ | តាមរយៈ គ.ជ.ប (មិនគិតលិខិតអញ្ជើញ) | 8 | 0.8% |
| ១២ | កាសែត | 9 | 0.9% |
| ១៣ | តាមរយៈប្រព័ន្ធទូរស័ព្ទ/អ៊ីនធឺណេត | 3 | 0.3% |
| ១៤ | តាមរយៈសកម្មជន ឬតំណាងគណបក្សនយោបាយ | 1 | 0.1% |
| | **សរុប** | 958 | 100.0% |

តាមលទ្ធផលដូចបានបង្ហាញក្នុងតារាងទី៤ ខាងលើ មេភូមិ ឬអនុភូមិ រួមទាំងអាជ្ញាធរមូលដ្ឋានផ្សេងទៀត នៅតែជាមធ្យោបាយសំខាន់សម្រាប់ការផ្តល់ព័ត៌មានទាក់ទងការចុះឈ្មោះបោះឆ្នោត។ ករណីនេះបង្ហាញថាអាជ្ញាធរត្រូវប្រកាន់ជំហរជាអ្នកឯករាជ្យក្នុងកិច្ចការនយោបាយ តាមរយៈការផ្តល់ព័ត៌មានដល់គ្រប់អ្នកបោះឆ្នោត និងគ្រប់និន្នាការនយោបាយ បើមិនដូច្នោះទេអ្នកបោះឆ្នោតនៅតែបាត់ព័ត៌មានពីការបោះឆ្នោត។

## ច. ការឆ្លើយតបរបស់ក្រុមការងារបច្ចេកទេសតំណាងឱ្យស្ថាប័ន គ.ជ.ប

ក្រោយពីការសិក្សាលើបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០១៩ ខុមហ្វ្រែលបានរៀបចំលទ្ធផលសង្ខេបនៃការរកឃើញ និងអនុសាសន៍ដាក់ទៅស្ថាប័ន គ.ជ.ប នៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០។ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ ខុមហ្វ្រែល ត្រូវបានក្រុមការងារបច្ចេកទេស គ.ជ.ប ដឹកនាំដោយឯកឧត្តម **សោម សូរីដា** អគ្គលេខាធិការរង និងជាតំណាងឱ្យស្ថាប័ន គ.ជ.ប បានអនុញ្ញាតឱ្យក្រុមការងារបច្ចេកទេសរបស់ខុមហ្វ្រែល បង្ហាញពីលទ្ធផលនៃការរកឃើញ និងបន្តជជែកពិភាក្សាគ្នាបន្ថែម។

បន្ទាប់ពីការបង្ហាញលទ្ធផល ឯកឧត្តម បានធ្វើការចំណាប់អារម្មណ៍ ដូចខាងក្រោម៖

- សូមអរគុណចំពោះអង្គការខុមហ្វ្រែលដែលខិតខំសិក្សាស្រាវជ្រាវ ផ្តល់ជាអនុសាសន៍ រួមទាំងលទ្ធផលនៃការរកឃើញ
- ទទួលយកតួលេខដែលបានរកឃើញដោយអង្គការខុមហ្វ្រែល និងបន្តសិក្សាកែសម្រួល
- បញ្ហាឈ្មោះស្ទួនជាកង្វល់មួយរបស់ស្ថាប័ន គ.ជ.ប ដែលត្រូវយកចិត្តទុកដាក់ខ្ពស់
- បញ្ហាដែលកើតមានលើឯកសារបញ្ជាក់អត្តសញ្ញាណវាជាកំហុសបច្ចេកទេស
- គ.ជ.ប បានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការចុះឈ្មោះបោះឆ្នោតអ្នកចំណាកស្រុកនៅក្រៅប្រទេស តែរង់ចាំតែច្បាប់អនុញ្ញាតឱ្យប៉ុណ្ណោះ

ក្នុងការបកស្រាយបន្ថែម ឯកឧត្តម **តុប វុទ្ធី** ប្រធាននាយកដ្ឋានគ្រប់គ្រងទិន្នន័យអ្នកបោះឆ្នោត និងបញ្ជីឈ្មោះបោះឆ្នោត បានបញ្ជាក់បន្ថែមថា៖

- ការរកឃើញរបស់ខុមហ្វ្រែលដែលបានរកឃើញអ្នកបោះឆ្នោតប្រើប្រាស់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរប្រភេទទី៣ ហើយស្ទួនគ្នានោះ វាមិនមែនជាកំហុសរបស់ក្រសួងមហាផ្ទៃនោះទេ វាជាកំហុសបច្ចេកទេសរបស់ គ.ជ.ប ដែលធ្វើឱ្យស្ទួន ហើយ គ.ជ.ប និងធ្វើការពិនិត្យ និងកែសម្រួលឡើងវិញ
- ឈ្មោះស្ទួនដែលកើតមាននៅក្នុងបញ្ជីឈ្មោះឆ្នាំ២០១៩ មានទិន្នន័យខ្លះសល់ពីឆ្នាំ២០១៨ ដែលលុបមិនទាន់បានអស់
- ចំពោះឯកសារដែលមានលេខស្មើ ០០០០ នៃអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងបញ្ជីឈ្មោះបោះឆ្នោតនោះគឺមកពីលេខអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មើលលេខមិនច្បាស់លាស់ ហេតុនេះភារីកុំព្យូទ័រត្រូវសរសេរលេខ០ ដើម្បីឱ្យប្រព័ន្ធអាចដំណើរការបាន
- គ.ជ.ប បានស្នើសុំទិន្នន័យឈ្មោះស្ទួន និងលេខសំគាល់ស្ទួនទាំងអស់ដែល ខុមហ្វ្រែលបានរកឃើញ ដើម្បីងាយស្រួល គ.ជ.ប ធ្វើការ (ខុមហ្វ្រែលបានសម្រេចឱ្យទៅ គ.ជ.ប)

ឆ្លើយតបជាមួយការរកឃើញនេះ ឯកឧត្តម **សោម សូរីដា** បានបញ្ជាក់ថា គ.ជ.ប និងចេញលិខិតជាផ្លូវការទៅអង្គការខុមហ្វ្រែល ដើម្បីឆ្លើយតបចំពោះអ្វីដែលខុមហ្វ្រែលបានរកឃើញ។

## ឆ. បញ្ហាប្រឈម និងដំណោះស្រាយ

ការចុះសម្ភាសន៍ប្រជាពលរដ្ឋនៅមូលដ្ឋាន បានចូលរួមសហការជាមួយ គ.ជ.ប សកម្មភាពទាំងឡាយនៃការចុះសម្ភាសន៍បានផ្តល់ព័ត៌មានទៅគ្រប់លេខាធិការរាជធានី ខេត្តរៀបចំការបោះឆ្នោត ដោយ គ.ជ.ប។ ក្នុងការអនុវត្តជាក់ស្តែង ការចុះសម្ភាសន៍ប្រជាពលរដ្ឋនៅមូលដ្ឋាន បានជួបនូវបញ្ហាប្រឈមមួយចំនួនពីអាជ្ញាធរមូលដ្ឋាន ទោះបីមានការចូលរួមសហការដោយ គ.ជ.ប និងមានសេចក្តីណែនាំពីក្រសួងមហាផ្ទៃពីការអនុវត្តសកម្មភាពយ៉ាងណាក៏ដោយ បញ្ហាទាំងនោះមានដូចខាងក្រោម៖

### បញ្ហាប្រឈម

សវនកម្មបញ្ជីឈ្មោះបោះឆ្នោតជាសកម្មភាពមួយដែលមានកិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន គ.ជ.ប។ ទោះបីមានការសហការក៏ដោយ បញ្ហាប្រឈមនៅតែកើតមានចំពោះការអនុវត្តន៍សកម្មភាពនៅមូលដ្ឋានដូចករណីខាងក្រោម៖

- **ខេត្តកំពង់ឆ្នាំង៖** អ្នកស្ម័គ្រចិត្តរបស់ខុមហ្វ្រែល ដែលត្រូវចុះសម្ភាសន៍ប្រជាពលរដ្ឋនៅក្នុងភូមិកំពង់ត្រឡាចក្រោម ឃុំកំពង់ត្រឡាច ស្រុកកំពង់ត្រឡាច កាលពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ត្រូវបានអាជ្ញាធរមូលដ្ឋាន មានមេភូមិ មេឃុំ ហាមឃាត់មិនឱ្យចុះធ្វើការសម្ភាសន៍ប្រជាពលរដ្ឋ ដោយសំអាងថា គ្មានកាតសម្គាល់ខ្លួនជាបុគ្គលិកខុមហ្វ្រែល គ្មានអត្តសញ្ញាណប័ណ្ណ និងគ្មានលិខិតអនុញ្ញាតពីឃុំ ស្រុក ខេត្ត បើទោះបីអ្នកស្ម័គ្រចិត្តមានលិខិតបេសកកម្មដែលចាត់តាំងដោយអង្គការ និងលិខិតទទួលស្គាល់អ្នកសង្កេតការណ៍ដោយ គ.ជ.ប ក៏ដោយ។
- **ខេត្តរតនៈគិរី:** អ្នកស្ម័គ្រចិត្តខុមហ្វ្រែល ដែលត្រូវចុះសម្ភាសន៍ប្រជាពលរដ្ឋនៅក្នុងភូមិណងហៃ នៅក្នុងឃុំសេដា ស្រុកលំផាត់ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៥ ត្រូវបានមេភូមិទទួលបញ្ជាពីលោកអភិបាលស្រុក នូ ថេរ ហាមឃាត់មិនឱ្យសម្ភាសន៍ប្រជាពលរដ្ឋ។ ការផ្អាកនេះសំអាងថាមិនបានសុំការអនុញ្ញាតពីសាលាខេត្ត និងឱ្យរង់ចាំមានការអនុញ្ញាតសិន បើទោះបីអ្នកស្ម័គ្រចិត្តខុមហ្វ្រែលមានលិខិតបេសកកម្ម លិខិតជាអ្នកសង្កេតការណ៍ចេញដោយ គ.ជ.ប លិខិតបញ្ជាក់ការសហការពី គ.ជ.ប និងលិខិតរបស់ក្រសួងមហាផ្ទៃប្រកាសពីការធ្វើសកម្មភាពដោយមិនចាំបាច់សុំច្បាប់យ៉ាងណាក៏ដោយ។ន័យមួយចំនួនត្រូវបានបាត់បដោយ

### ការដោះស្រាយ

ករណីខេត្តកំពង់ឆ្នាំង និងខេត្តរតនៈគិរី ត្រូវបានដោះស្រាយដោយមានការចូលរួមអន្តរាគមន៍ ពីលេខាធិការដ្ឋានខេត្តរៀបចំការបោះឆ្នោត។ ខេត្តរតនៈគិរី ត្រូវបានអនុញ្ញាតឱ្យធ្វើការសម្ភាសន៍ក្រោយពីមានការអន្តរាគមន៍ តែខេត្តកំពង់ឆ្នាំង ក្រោយពីមានការផ្អាកសកម្មភាពពីអាជ្ញាធរមក ទោះបីមានការអនុញ្ញាតឱ្យធ្វើឡើងវិញក៏ដោយ តែប្រជាពលរដ្ឋដែលជាអ្នកបោះឆ្នោតគោលដៅត្រូវសម្ភាសន៍ទាំងអស់មិនសហការក្នុងការផ្តល់បទសម្ភាសន៍នោះទេ។ ករណីខេត្តកំពង់ឆ្នាំងនេះ អ្វីដែលកត់សំគាល់គឺមុនពេលដែលផ្អាកសកម្មភាពនេះ មេភូមិ មេឃុំ បានពិនិត្យ និងដឹងថាអ្នកណាត្រូវសម្ភាសន៍ជាមុនរួចហើយ តែក្រោយមកពេលដែលអ្នកស្ម័គ្រចិត្តចុះសម្ភាសន៍ មេភូមិបានទៅឃាត់មិនឱ្យសម្ភាសន៍វិញ។